# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ ភួង ភី ភេទស្រី អាយុ៥៥ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ “កាត់ដេរ”**

**ស្រុកកំណើតនៅភូមិបន្ទាយ ឃុំគោលាប់ ស្រុកក្រចេះ ខេត្តក្រចេះ**

**រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ចាន ប្រុញ និង សុខ វណ្ណៈ**

**០១:០៧:០៣**

**២៩ទំព័រ**

ប្រុញៈ ចឹងសូមជំរាបសួរអ៊ំសារជាថ្មី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងគឺក្នុងគោលបំណង ចងក្រងឯកសារពាក់ព័ន្ធជីវិតតស៊ូរបស់អ៊ំ មកដល់រាល់ថ្ងៃហ្នឹងហើយមកនៅឃុំស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យហ្នឹងចង់សួរថា ពាក់ព័ន្ធនិងជីវិតតស៊ូរបស់អ៊ំដើម្បីចងក្រងជាឯកសារទុកឲ្យកូនចៅជំនាន់ក្រោយឲ្យបានរៀនសូត្រចឹង ចឹងអ៊ីដែលខ្ញុំបានសម្ភាសអ៊ំពេលនេះ ខ្ញុំអាចយកទៅសរសេរដើម្បីណែនាំឬអាចយកទៅប្រើប្រាស់ផ្សេងៗឲ្យកូនចៅបានរៀនផងបានទេអ៊ំ?

ភីៈ ចុះមានអី ។

ប្រុញៈ ចឹងខ្ញុំសុំថតជាសម្លេងដើម្បីងាយស្រួលក្នុងការកត់ត្រាបន្ថែមទៀត ចឹងខ្ញុំចង់សួរអ៊ំ មានស្រុកកំណើតនៅក្នុងភូមិឃុំណាដែរ?

ភីៈ ខ្ញុំនៅស្រុកក្រចេះ ឃុំគោលាប់ ភូមិបន្ទាយ ។

ប្រុញៈ ខេត្តអីគេ?

ភីៈ ខេត្តក្រចេះ ស្រុកប្រចេះតែម្តង ។

ប្រុញៈ ចឹងអ៊ំរៀនសូត្រដល់ណាដែរ?

ភីៈ ចុះយើងពីដើមរៀនបានថ្នាក់ទី១២ហ្នឹង ។

ប្រុញៈ ចឹង១២សម័យមុន?

ភីៈ ចាស ។

ប្រុញៈ ចឹងកាលហ្នឹងអ៊ំរៀនដល់ឆ្នាំណាដែរ?

ភីៈ ខ្ញុំរៀនបានតែមួយឆ្នាំស្រុកមានរដ្ឋប្រហារបណ្តោយ ។

ប្រុញៈ ចឹងមានរដ្ឋប្រហារអ៊ំឈប់រៀន?

ភីៈ ចាស ។

ប្រុញៈ	រដ្ឋប្រហារឆ្នាំ១៩៧០?

ភីៈ	ឆ្នាំ៧០ហ្នឹង ។

ប្រុញៈ	ចឹងបន្ទាប់ពីរដ្ឋប្រហារទៅអ៊ីឈប់រៀនអ៊ីទៅណាវិញអ៊ី?

ភីៈ	ខ្ញុំទៅផ្ទះវិញ ខ្ញុំមករៀននេះខ្ញុំមកនៅជាមួយយាយខ្ញុំនៅគគរ ដល់ហើយស្រុករដ្ឋប្រហារខ្ញុំទៅនៅជាមួយម៉ែខ្ញុំអីគោលាប់វិញភូមិបន្ទាយវិញ ។

ប្រុញៈ	ចឹងរដ្ឋប្រហារហើយអ៊ីមានបានចូលក្នុងចលនារបស់ខ្មែរក្រហមឬមួយយ៉ាងម៉េចអ៊ី?

ភីៈ	ខ្ញុំកាលរដ្ឋប្រហារហ្នឹងខ្ញុំអត់ទាន់ចូលទៅ ខ្ញុំទៅនៅផ្ទះវិញហ្នឹងខ្ញុំនៅក្នុងកុមារឃុំ ។

ប្រុញៈ	បាទ ។

ភីៈ	នៅកុមារឃុំខ្ញុំនេះ ទៅនៅហ្នឹងទៅបានមេឃុំហ្នឹងគាត់ឲ្យរើសកុមារហ្នឹង រៀនហាត់សិល្បៈនៅឃុំណាស់ ។

ប្រុញៈ	បាទ ។

ភីៈ	អាហ្នឹង៧១-៧២ដល់៧៣បានគេឲ្យខ្ញុំចូលជានារី ។

ប្រុញៈ	ចឹងមានន័យថា ៧១-៧២ហ្នឹងនៅកុមារ?

ភីៈ	នៅកុមារ ។

ប្រុញៈ	នៅកុមារអាយុប្រហែលជាប៉ុន្មាន?

ភីៈ	ខ្ញុំអាយុ១៧ឆ្នាំ ។

ប្រុញៈ	អាយុ១៧ហ្នឹងគេឲ្យអ៊ីរើសកុមារដើម្បីធ្វើសិល្បៈ?

ភីៈ	ចាស!ដល់ពេលមក៧៣បីនេះខ្ញុំចូលនារី ចូលនារីហើយខ្ញុំនៅអគ្គភាពនារីភូមិហ្នឹងដល់ហើយទៅបានមួយឆ្នាំកន្លះឆ្នាំបានមេភូមិហ្នឹងឲ្យខ្ញុំទៅជួយមើលប្រជាជននៅតាមសហករណ៍ ។

ប្រុញៈ	មេភូមិហ្នឹងឈ្មោះអីគេអ៊ី?

ភីៈ	មេភូមិហ្នឹងជីតាគាត់មិនដឹងឈ្មោះអីទេ គាត់ហ្នឹងឈ្មោះ សំ តែគាត់ស្លាប់បាត់ហើយឥឡូវមិនដែលឃើញ ។

ប្រុញៈ	គាត់នៅក្រចេះហ្នឹង?

ភីៈ	ចាស!គាត់នៅឃុំគោលាប់ ភូមិបន្ទាយហ្នឹងតែម្តង ផ្ទះគាត់ស្រុកកំណើតគាត់នៅហ្នឹង ។

ប្រុញៈ	ចឹងយ៉ាងម៉េចបានគេឲ្យអ៊ីជ្រើសរើនារីដើម្បីអីអ៊ី?

ភីៈ	កាលហ្នឹងគេរឿសហ្នឹងនៅកងចល័តណាស់ កងចល័តភូមិដល់ពេលប្រជាជនធ្វើស្រែកន្លែងណាអត់រួចហ្នឹងយកនារីមកឲ្យគេជួយ ជួយដកជួយស្ទូងរគាត់ឲ្យឆាប់ហើយចឹងទៅ ។

ប្រុញៈ	ចឹងឆ្នាំ៧៣ហ្នឹងធ្វើការខាងនារីហ្នឹង?

ភី៖ ខ្ញុំនៅកងនារី ខ្ញុំជាសមាជិកគេតែម្ដង អត់មានប្រធានអត់មានអីទេ ។

ប្រុញ៖ ចឹងប្រធានឈ្មោះអីគេអ៊ី?

ភី៖ ប្រធានកាលនោះភ្លេចអស់ហើយខ្ញុំ វាមិនសូវចាំដែរ ។

ប្រុញ៖ ចឹងចន្លោះឆ្នាំ៧៣ហ្នឹងអ៊ីនៅធ្វើស្រែធម្មតា?

ភី៖ ចាស!ខ្ញុំនៅធ្វើស្រែដល់មក៧៣-៧៤នេះបាននៅក្នុងសហករណ៍៧៤-៧៥ហ្នឹងនៅក្នុងសហករណ៍ ។

ប្រុញ៖ នៅសហករណ៍នៅក្នុងឃុំ?

ភី៖ សហករណ៍ក្នុងភូមិហ្នឹង ដល់មក៧៦បានខ្ញុំមកនៅស្រុក ។

ប្រុញ៖ ស្រុកអីគេ?

ភី៖ ស្រុកក្រចេះហ្នឹង នៅស្រុកហ្នឹងបានមួយខែគេបញ្ជូនខ្ញុំឲ្យមកនៅតំបន់នេះ នៅតំបន់តែប៉ុន្មានថ្ងៃបានគេបញ្ជូនទៅនៅភ្នំពេញ ទៅរៀនកាត់ដេរ ។

ប្រុញ៖ នៅក្នុងឆ្នាំណា?

ភី៖ នៅក្នុងឆ្នាំ៧៦ហ្នឹង រៀនកាត់ដេរនៅភ្នំពេញ នៅផ្សារអូរប្ញស្សីហ្នឹងដល់ពេល៧៨ពាក់កណ្ដាល៧៨ហ្នឹងគេបញ្ជូនខ្ញុំមកនៅស្រុកវិញ ។

ប្រុញ៖ នៅស្រុកអីគេ?

ភី៖ ស្រុកក្រចេះហ្នឹងដដែល ដល់៧៩នេះរត់ យួនចូលស្រុកនោះ ។

ប្រុញ៖ ចឹង៧៩ហ្នឹង?

ភី៖ នៅតំបន់ដដែលហ្នឹង ដល់ពេលយួនចូលស្រុកមកយើងមិនរត់ រត់មកដល់ចម្ការលើនេះបានប៉ុន្មានថ្ងៃខ្ញុំបកមកផ្ទះវិញ ដល់នៅផ្ទះបានតែកន្លះខែហើយបានខ្ញុំចូលព្រៃ ។

ប្រុញ៖ ចឹង៧៩អ៊ីរត់មានខាងណា?

ភី៖ យួនចូលទូទាំងប្រទេសយើងមិនរត់ រត់ចេញពីតំបន់អាខ្លះទៅនេះអាខ្លះទៅនោះ ។

ប្រុញ៖ ចឹងតំបន់ហ្នឹងតំបន់ប៉ុន្មាន?

ភី៖ នៅក្រចេះតំបន់ក្រចេះហ្នឹងតែម្ដង ដល់ពេលយើងរត់មកលិចនេះឆ្លងទន្លេមកខ្ញុំមកម្ដុំព្រៃកប្រសព្វណាស់ នៅម្ដុំព្រៃកប្រសព្វខ្ញុំនៅប្រហែលជាបាន១០ថ្ងៃ គណៈស្រុកគេមិនដឹងទ័ពមិនដឹងទេ ក៏ផ្សាយតាមវិទ្យុនោះ អ្នកណានៅអគ្គភាពណាឲ្យទៅនៅអគ្គភាពហ្នឹង នៅតំបន់ណាឲ្យទៅនៅតំបន់ហ្នឹង ខ្ញុំមិនបកទៅតំបន់ខ្ញុំវិញ ។

ប្រុញ៖ ចឹងឆ្នាំ៧៩?

ភី៖ ចាស!ឆ្នាំ៧៩ ។

វណ្ណៈ	ចឹងកាលដែលអ៊ំនៅស្រុកក្រចេះហ្នឹងគណៈតំបន់ណាគេអ៊ំមានស្គាល់ទេ?

ភី:	ចឹងតំបន់ហ្នឹងភ្លេចឈ្មោះហើយ យូរហើយឈ្មោះតាអីទេ គណៈតំបន់ហ្នឹងភ្លេចឈ្មោះ ។

វណ្ណៈ	ចឹងគណៈស្រុក?

ភី:	គណៈស្រុកក៏ភ្លេច វាយូរហើយតាំងពីនោះមក ហើយយើងមិនសូវបានព្យាយាមនឹកនា ។

វណ្ណៈ	កាលហ្នឹងគេឲ្យអ៊ំធ្វើអីដែរ?

ភី:	ខ្ញុំនៅកាត់ដេរ ។

វណ្ណៈ	កាត់ដេរនៅក្រចេះហ្នឹង?

ភី:	ចាស! នៅតំបន់ហ្នឹង ។

ប្រុញៈ	ឆ្នាំ៧៩?

ភី:	យើងតាំងពី៧៦ទៅយើងមករៀននៅភ្នំពេញផ្សារអូរឬស្សីនេះ ដល់ពេល៧៨ហ្នឹងយើងមិនទៅវិញ ។

វណ្ណៈ	ចឹង៧៦ហ្នឹងគេឲ្យទៅរៀននៅភ្នំពេញ?

ភី:	ចាស ។

វណ្ណៈ	រៀនអីគេ?

ភី:	រៀនកាត់ដេរ ។

វណ្ណៈ	កាត់ដេរហ្នឹងពីណាមកបង្រៀនយើងទៅ?

ភី:	កាត់ដេរកាលហ្នឹងនៅជាមួយតាធុច ទទួលខុសត្រូវនៅកន្លែងកាត់ដេរនៅផ្សារអូរឬស្សីហ្នឹង ។

វណ្ណៈ	ចឹងមីងទៅនៅភ្នំពេញហ្នឹងបានរយៈពេលប៉ុន្មានដែរ?

ភី:	ខ្ញុំទៅខែ៦ឆ្នាំ៧៦ហ្នឹង ដល់មកខែ៨ឆ្នាំ៧៧នេះ ខ្ញុំមកវិញ ។

វណ្ណៈ	យ៉ាងម៉េចបានមីងមកវិញ?

ភី:	ចុះគេឲ្យទៅរៀន រៀនចេះគេឲ្យមកតំបន់វិញ មកធ្វើការនៅតំបន់វិញនោះ កាត់ខោអាវនៅតំបន់វិញ ។

វណ្ណៈ	ចឹងកាលហ្នឹងប្រធានកាត់ដេរអីមីងមានស្គាល់ទេ?

ភី:	ប្រធានកាត់ដេរទទួលខុសត្រូវនៅហ្នឹងឈ្មោះ បងរ៉ាន់ ។

ប្រុញៈ	ចឹងបន្ទាប់មកទៀត?

ភី:	បន្ទាប់មកទៀតគ្នាឯងហ្នឹងតែភ្លេចឈ្មោះហើយ ។

វណ្ណៈ	ចឹងមីងមានតួនាទីអីដែលកាលហ្នឹង?

ភី:	ខ្ញុំអត់ទេ ។

ប្រុញៈ ចឹងអ៊ីធ្លាប់បានជួបតាធុច ហ្នឹងដែរ?

ភីៈ តាធុច ហ្នឹងឮតែឈ្មោះទេ មិនដែលឃើញមុខទេ ។

ប្រុញៈ ចឹង?

ភីៈ ទទួលខុសត្រូវនៅហ្នឹងឮតែឈ្មោះទេ និយាយរួមទៅខ្ញុំម៉ាជំនាន់ហ្នឹងខ្ញុំមិនសូវហ៊ានណាស់ ខ្ញុំមិនសូវហ៊ានទេ អ្នកធំអ្នកតូចអីខ្ញុំមិនសូវក្របេ៉កក្រប៉ុកអីខ្ញុំគេឲ្យធ្វើអីខ្ញុំធ្វើហ្នឹង ខ្ញុំអត់អ្នកព្យាយាម ។

ប្រុញៈ ចឹងពីរៀនកាត់ដេរគេមានឲ្យអ៊ីរៀនអីទៀតអត់?

ភីៈ អត់មានរៀនទេ ។

ប្រុញៈ អត់មានធ្លាប់ចូលប្រជុំជាមួយគេ?

ភីៈ ប្រជុំទូទៅតែម្ដងប្រជុំ ។

ប្រុញៈ គេប្រជុំនិយាយពីរឿងអីទៅ?

ភីៈ គេប្រជុំអប់រំយើងរឿងធ្វើការងារអីហ្នឹងណា ។

ប្រុញៈ គេអប់រំយ៉ាងម៉េចទៅអ៊ី?

ភីៈ គេថា គេពន្យល់ឲ្យយើងដេរចឹងឲ្យយើងយកចិត្តទុកដាក់ដេររបស់របរឲ្យស្អាត ឲ្យចេះសម្អាត ឲ្យយើងចេះសន្សំសំចៃកុំឲ្យខ្ជះខ្ជាយណាស់ កុំឲ្យយើងខ្ជះខ្ជាយដូចជាកំទេចអំបោះកំទេចក្រណាត់ហ្នឹងណាស់ ដូចថាយើងត្រូវធ្វើអីកើតយកមកយើងឆ្នៃប្រឌិតធ្វើចឹងទៅ គេមិនយើងខ្ជះខ្ជាយរបស់របរចឹង ត្រូវចេះសន្សំសំចៃ ។

ប្រុញៈ ចឹងរៀនហ្នឹងសុទ្ធតែខ្មែរយើងសុទ្ធតើ?

ភីៈ ខ្មែរយើងហ្នឹង ។

ប្រុញៈ មានវៀតណាមអីទេ?

ភីៈ អត់មានទេ ខ្ញុំមិនដែលស្គាល់ផង ។

ប្រុញៈ ចឹងជនជាតិចាមអី?

ភីៈ ទេ មិនដែលស្គាល់ទេ និយាយពួកយើងអ្នកស្រុកហ្នឹងដូចថា អ្នកខ្លះនៅស្រុកសំបូរចឹងទៅអ្នកខ្លះនៅស្នួល ខ្លះនៅក្រចេះណាស់ ក្នុងមួយស្រុកដូចគេយកពីរនាក់អីចឹង ដូចថាស្រុកសំបូរណ៍ចឹងគេយកប្រុសមួយស្រីមួយ គេយកគ្រប់ស្រុក ។

ប្រុញៈ ចឹងដល់បែកភ្នំពេញ?

ភីៈ បែកភ្នំពេញ ។

ប្រុញៈ ចឹងបែកភ្នំពេញមកស្រុកអ៊ីវិញ?

ភីៈ ចាស ។

ប្រុញៈ មកកាត់ដេរហ្នឹងរហូតប្ញមួយយ៉ាងម៉េច?

ភីៈ ដល់ពេលនេះគេបញ្ជូនមកនៅតំបន់ ពេលយួនចូលស្រុកនេះ ហ្នឹងខ្ញុំនៅក្នុងតំបន់ដែរ ។

ប្រុញៈ ចឹងនៅធ្វើអីគេនៅហ្នឹង?

ភីៈ ខ្ញុំនៅដេរហ្នឹង ដល់ពេលយួនចូលស្រុកមកវា អាហ្នឹងវាទូទាំងប្រទេសហើយ ដល់ហើយយើងមិនរត់ចេញ រត់ចេញចឹងទៅទំរាំតែបានប្រហែលជាមួយខែចឹងទៅ មួយខែបានយើងចូលមកតំនប់វិញ យើងមកនៅតំបន់វិញ ខ្ញុំខ្ជិលនៅ បែកខ្ញែកគ្នាអស់ហើយខ្ញុំទៅនៅផ្ទះ នៅផ្ទះដល់ហើយមិនយួនចូលស្រុក ។

ប្រុញៈ បាទ ។

ភីៈ យួនចូលស្រុកក៏ខ្ញុំចេញនេះទៅ ខ្ញុំចូលព្រៃទៀតមក ។

ប្រុញៈ ម៉េចបានអ៊ីចូលព្រៃចឹងអ៊ី?

ភីៈ កាលហ្នឹងមូលហេតុចេះអូន ហ្នឹងយើងនិយាយតាមការជាក់ស្តែងតាមខ្លួនយើងផ្ទាល់តែម្តងដូចថាក្នុងផ្ទះដូចផ្ទះខ្ញុំចឹង មានកូនក្រមុំចឹង ដូចយើងទៅដួតទឹកត្រឹមដើមឈើនោះ ដល់ចឹងទៅយួនវាទៅតាម របៀបថាទៅញ៉ែអីចឹង វាចាប់យើងចាប់អីទៅដល់ហើយឃើញចឹងខ្ញុំខ្លាចខ្ញុំអត់ហ៊ាននៅ ខ្ញុំចូលព្រៃមក ។

ប្រុញៈ យួនទៅដល់ហ្នឹងដែរ?

ភីៈ សម្បូរណាស់ ចុះក្រចេះនិងព្រំប្រទល់យួនវាមិនជិតគ្នា ។

ប្រុញៈ បាទ ។

ភីៈ ស្រុកស្នួលអាអូនឯងមិនដែលឮគេនិយាយទេ ទៅពីស្នួលទៅមុំអីទេខាងកើតហ្នឹង ។

ប្រុញៈ ចឹងកាលហ្នឹងយួនវាចូលទៅមានធ្វើបាបដែលអត់ទេ?

ភីៈ អត់ទេ គ្រាន់មកសួរយើង យើងអត់ម៉េះម៉ោះទៅ យើងមកផ្ទះយើងវិញទៅ ។

ប្រុញៈ ហ្នឹងនៅក្នុងឆ្នាំណាដែរ?

ភីៈ នៅឆ្នាំ៧៩ហ្នឹង ។

ប្រុញៈ យួនមានច្រើនទេ នៅកន្លែងអ៊ីហ្នឹងមានយួនច្រើនទេ?

ភីៈ មានមួយនាក់ពីរនាក់ មិនមានទៅច្រើនទេ ។

ប្រុញៈ កាលហ្នឹង ទាហានប្ញយ៉ាងម៉េចអ៊ីប្ញប្រជាជនធម្មតា?

ភីៈ ទាហានយួនហ្នឹងណាស់ ។

ប្រុញៈ មានប្រជាជនធម្មតាទេ?

ភីៈ យួនជាទាហាន ។

ប្រុញៈ សុទ្ធតែទាហានតែម្តង?

ភីៈ ចាស!ទាហាន ។

ប្រុញៈ ដល់ចឹងទៅប្រជាជនដែលនៅក្នុងតំបន់អ៊ឹហ្នឹងរត់ចូលព្រៃទៅ?

ភីៈ គាត់មិនរត់ទេ រត់តែដូចខ្ញុំអី ខ្ញុំធ្លាប់មកធ្វើកងនារីអីចឹង ដល់ពេលឃើញចឹងខ្ញុំខ្ចិល ខ្ញុំចេញមក ក្រោមកតាមពូៗទៅណាស់ មកតាមទ័ពយើង ចេញមកព្រៃមក ។

ប្រុញៈ អ៊ឹចូលតាមពីណាគេ?

ភីៈ ឈ្មោះ យឿន ។

ប្រុញៈ យឿន ហ្នឹងប្រាប់អ៊ឹថាយ៉ាងម៉េច?

ភីៈ យឿន ប្រាប់ថាយើងចូលព្រៃចឹង ខ្លាចយួនវាចាប់ធ្វើបាបបេះចុះណាស់ ក៏យើងចូលទៅ ចូលទៅជាមួយគេទៅក៏ខ្ញុំនៅហ្នឹងរហូតតាំងពីឆ្នាំ៧៩មក ។

ប្រុញៈ យឿន ហ្នឹងគាត់ធ្វើអីគេដែរ?

ភីៈ យឿន ហ្នឹងសេនាជនយើងធម្មតា សេនាជនភូមិ ។

ប្រុញៈ គាត់ប្រាប់ថាយ៉ាងម៉េច?

ភីៈ ខ្ញុំហ្នឹងយួនវាមកប្រាជ្ញព្រោកនិយាយជាមួយយើងឲ្យយើងស្រឡាញ់វាអីចឹង ហើយខ្ញុំហ្នឹងក៏ សួរគាត់ ខ្ញុំសួរគាត់ គាត់ថាឯងបើនៅចឹងទៅចូលព្រៃជាមួយទ័ពទៅ ក៏ខ្ញុំទៅ ។

ប្រុញៈ ពេលហ្នឹងអ៊ឹរៀបការហើយនៅ?

ភីៈ នៅទេ ខ្ញុំអាយុទើប១៧មិនទាន់ទេ ។

ប្រុញៈ យឿន ហ្នឹងគាតធ្វើសេនាជន?

ភីៈ បើឥឡូវយើងថាឈ្លបភូមិណាស់ ជំនាន់ហ្នឹងគេហៅសេនាជន ។

ប្រុញៈ ចឹងអ៊ឹមានដឹងថា អ្នកដែលធំជាង យឿន ហ្នឹងមានពីណាគេ?

ភីៈ ខ្ញុំចេញពីតំបន់យូរហើយក្នុងភូមិខ្ញុំមិនសូវនៅខ្ញុំទៅនៅជាមួយយាយខ្ញុំនោះ ។

ប្រុញៈ ចឹងអ៊ឹចូលមកនៅព្រៃជាមួយ យឿន ហ្នឹង?

ភីៈ អត់ទេ គាត់អត់ចូលទេ គាត់ទៅផ្ទះវិញ ឥឡូវគាត់ស្លាប់បាត់ហើយ យួនវាយស្លាប់ ។

ប្រុញៈ យួនវាយ?

ភីៈ ចាស!យួនធ្វើបាប កាលហ្នឹងខ្ញុំប្រាប់ទៅប្រវត្តិយើងជំនាន់ហ្នឹងវាយ៉ាប់ដែលបើកូនៗចូលព្រៃ ម៉ែឪនៅផ្ទះយួនចាប់ធ្វើបាបដែលហ្នឹង ដល់ចឹងឪពុកខ្ញុំអត់ហ៊ានប្រាប់ថា ខ្ញុំនៅព្រៃទេ គាត់ លាក់ដែលហ្នឹង ។

ប្រុញៈ ចឹងពេលយួនដឹងថា មានកូនចៅនៅព្រៃធ្វើបាបអ្នកផ្ទះនេះ?

ភីៈ ចាស!ធ្វើបាបអ្នកផ្ទះ ដល់ចឹងខ្ញុំអត់មានប្រាប់ថា ខ្ញុំនៅព្រៃនៅអី សំបុត្រស្នាមក៏ខ្ញុំមិនដែលផ្ញើរដែរ ។

ប្រុញៈ បាទ ។

ភីៈ មិនដែលផ្ញើរទេ ទាល់តែយើងផ្តាច់ខ្លួននេះ សមាហរណ៍កម្មនេះបានខ្ញុំទៅលេង ។

ប្រុញៈ ចឹងមានឃើញយួនចាប់ពីណាបានឃើញសម្លាប់ទេ?

ភីៈ អត់មានឃើញសម្លាប់ទេ ។

ប្រុញៈ ពេលចូលព្រៃ?

ភីៈ ហ្នឹងហើយអត់មានសម្លាប់ទេ មានតែពួៗទៅធ្វើការខាងមុខចឹងជួបគ្នាវាយគ្នានៅសមរភូមិអីអាហ្នឹងមាន ។

ប្រុញៈ ឆ្នាំក្រោយ៧៩ហ្នឹង?

ភីៈ ចាស!នៅក្នុងឆ្នាំ៧៩ហ្នឹង កាលហ្នឹងយើងមិនចូលធ្វើការតាមភូមិអីពួៗតែខ្ញុំនៅព្រៃនោះទេ ។

ប្រុញៈ បាទ ។

ភីៈ ខ្ញុំនៅតែព្រៃនោះ ។

ប្រុញៈ ចឹងកាលហ្នឹងមានដែលចាប់បានទាហានយួនអីទេ?

ភីៈ អត់ទេ ។

ប្រុញៈ ចឹងយួនមានដែលចាប់ទាហានខាងខ្មែរក្រហមទេ?

ភីៈ អត់សូវដឹងដែលខ្ញុំ ខ្ញុំសមរភូមិខ្ញុំមិនដែលមកដង ។

ប្រុញៈ ចឹងនៅក្នុងព្រៃចឹងអត់មានទាហានយួននៅជិតហ្នឹងទេ?

ភីៈ អត់ទេ!មានតែយើងទ័ពខ្មែរក្រហមហ្នឹងនារីៗហ្នឹង នៅជាមួយពួៗដែលយើងលាក់ខ្លួនចាំយើងទាក់ទងរករយៈបានហើយបានយើងឡើងមក ។

ប្រុញៈ ចឹងអ៊ំនៅក្នុងព្រៃហ្នឹងអ៊ំនៅយ៉ាងម៉េចដែរ យើងដាំបាយឲ្យពួៗអីយ៉ាងម៉េច?

ភីៈ យើងដាំហូបខ្លួនយើង ពួៗគេដាំរបស់គេទៅ ។

ប្រុញៈ តែនៅជុំគ្នាទៅ?

ភីៈ ចាស!នៅជុំគ្នា នៅដូចថាយើងនៅសម្រាកចឹងទៅ ពួៗគេនៅសម្រាកចឹងទៅមួយក្រុមមាននារីបីទៅបួននាក់ចឹងទៅ ។

វណ្ណៈ ខ្ញុំសូមកាត់បន្តិច កាលដែលអ៊ំរត់ចូលព្រៃហ្នឹង អ៊ំនៅម្តុំណា អ៊ំរត់ចូលព្រៃហ្នឹងមកដល់ភ្នំដងរែកឬនៅប្រក១០០១ឬនៅប្រកណាមួយ?

ភី:	ខ្ញុំនៅខាងរតនគិរីនោះ ។

វណ្ណៈ:	ចឹងនៅខាងរតនគិរីវិញ?

ភី:	ចាស! រត់ទៅហ្នឹងវិញ ។

វណ្ណៈ:	ចឹងពីណាដឹកនាំនៅខាងរតនគិរីហ្នឹង?

ភី:	អត់មានពីណាដឹកនាំទេ កាលហ្នឹង ចេញឲ្យតែរូបម៉ាសុខខួនតែម្តង ។

វណ្ណៈ:	ចឹងក្រោយមកទៀត?

ភី:	ក្រោយមកទៀតបានយើងរករយៈដឹង ។

វណ្ណៈ:	យើងចេញមកខាងណាវិញ?

ភី:	យើងរករយៈបានយើងប្រមូលផ្តុំហើយ ដល់ឆ្នាំ៨០នេះបានមានរយៈឡើងភ្នំ ។

វណ្ណៈ:	ភ្នំណា?

ភី:	ភ្នំដងរែកយើងហ្នឹង ខ្ញុំនៅមុំបី ។

ប្រុញ:	ចឹងនៅមុំបី?

ភី:	ចាស! ឡើងមកនៅមុំបី ។

ប្រុញ:	ហ្នឹងក្នុងឆ្នាំណាអី?

ភី:	ខ្ញុំឡើងមកនៅមុំបី៨១ ។

វណ្ណៈ:	ចឹងពេលមកដល់មុំបីហ្នឹងអីមានបានឃើញពីណាខ្លះដែរ?

ភី:	មុំបីខ្ញុំឡើងមកជាមួយ តាពីន ។

វណ្ណៈ:	តាពីន គាត់កាន់កងពលលេខប៉ុន្មាន?

ភី:	ខ្ញុំមិនដឹងជាកងពលលេខប៉ុន្មានទេ ខ្ញុំមិនដែលហ៊ានសួរអីគេផង ខ្ញុំនៅជាមួយប្រពន្ធគាត់ ប្រពន្ធគាត់មិនចូលទៅដែរ ។

វណ្ណៈ:	នៅមុំបីហ្នឹងមានប្រជាជនច្រើនទេ នៅហ្នឹង?

ភី:	មុំបីហ្នឹងប្រជាជនមានរាប់ពាន់គ្រួសារនោះណាស់ ។

វណ្ណៈ:	ហើយគេឲ្យប្រជាជនធ្វើអីខ្លះទៅ?

ភី:	ប្រជាជននៅមុំបីហ្នឹងមីងៗនៅហ្នឹងអត់មានធ្វើអីទេ គេឲ្យបិតចំរូងចឹងជួនក៏អត់ចឹងទៅដាំបាយហូបធម្មតា ។

វណ្ណៈ:	ចឹងប្រុសៗហ្នឹងចុះទៅសមរភូមិ?

ភី:	ប្រុសៗតាៗហ្នឹង អាយុ៤០ជាងគេឲ្យនៅជាមួយមីងៗ ។

វណ្ណៈ:	មុំបីហ្នឹងចំណុចវានៅ៨០៨ដែលឬមួយយ៉ាងម៉េច?

ភីៈ ហ្នឹងហើយមុំបី៨០៨នៅកើតហ្នឹង ជាមួយគ្នាកើតហ្នឹង ។

វណ្ណៈៈ ជាមួយគ្នាមុំបី៨០៨ហ្នឹង?

ភីៈ ចាស ។

វណ្ណៈៈ ចឹងយ៉ាងម៉េចបានគេដាក់ថាមុំបី មីងមានដឹងទេ?

ភីៈ មុំបីភ្នំវានៅជុំវិញហ្នឹង អាកណ្តាលហ្នឹងដូចជាបាតខ្ទះ អាលិចក៏ភ្នំខាងជើងក៏ភ្នំខាងកើតក៏ភ្នំ អាមកខាងត្បូងវាមាត់ជ្រោះដីយើង ។

វណ្ណៈៈ ជាប់ព្រំដែនប្រទេសណាខ្លះមុំបីហ្នឹង?

ភីៈ មុំបីហ្នឹងទៅខាងជើងថៃ ខាងកើតលាវឬគេថាលាវខាងកើត យើងនៅកណ្តាលខាងត្បូងយើងហ្នឹងហើយ ។

ប្រុញៈ ចឹងបានគេបង្កើតជាមុំបី?

ភីៈ ចាស ។

ប្រុញៈ ចឹងពេលហ្នឹងមានវៀតណាមចូលមកដល់មុំពីអីទេ?

ភីៈ អត់មានទេ វៀតណាមនៅដីយើងខាងក្រោមនេះហ្នឹង អត់មានចូលដល់ទេ ។

ប្រុញៈ ខ្ញុំចង់សួររឿងវៀតណាមវាយគ្នានៅចន្លោះ៨០ជាងដល់៩០ជាង នៅមុកអស់ហ្នឹង?

ភីៈ វាវាយតែនៅដីយើងនៅស្រែល្បញអី ស្រែកង់ទ័ពអីមុខនេះ មីងៗនៅខាងលើនោះអត់មានអីផងហ្នឹង ដល់ពេលមីងៗនៅលើនោះ មើល៨៤ អាហ្នឹងសមរភូមិគេនៅអីក្រោមអីអូន ។

ប្រុញៈ បាទ ។

ភីៈ តែគ្រាប់ផ្លោងវាផ្លោងទៅខាងលើ ដល់ហើយពួកយើងដកខ្លួនចេញមកនៅនេះ មកនៅ៨០៨ យើងនេះ នៅជងទង់អូរគ្រាវមុខយើងនេះ ដកមីងៗពីនោះមក មកនៅនេះវិញ ។

ប្រុញៈ ចឹងដកមកទាំងអស់គ្នា?

ភីៈ ចាស!ទាំងអស់តែម្តងប្រជាជនរាប់រយគ្រួសារមកនៅនេះទាំងអស់តែម្តង មកនៅជិតតាម៉ុកវិញហ្នឹង ។

ប្រុញៈ អីស្គាល់តាម៉ុក ច្បាស់ដែរ?

ភីៈ តាម៉ុក អីមិនស្គាល់ ។

ប្រុញៈ មានដែលបានប្រជុំនិយាយលេងសើចជាមួយគាត់ទេ?

ភីៈ មិនដែលនិយាយទេ តែគាត់ធ្លាប់ចុះទៅលេងកន្លែងយើងម្តងៗ តាដូចបារាំងចឹង ។

ប្រុញៈ គាត់ស?

ភីៈ សស្គុសដូចបារាំង ច្រមុះដូចបារាំងចឹង តាហ្នឹង ។

ប្រុញៈ ចឹងអត្តចរិកគាត់យ៉ាងម៉េចដែរ?

ភីៈ អត្តចរិកគាត់មានម៉េចធម្មតារបស់គាត់ហ្នឹង ធម្មតាគាត់និយាយលេងអី ធម្មតារបស់គាត់មិនដែលឃើញកើតអីផង ។

ប្រុញៈ គាត់កាចដែរ?

ភីៈ ថាកាចក៏ដូចមិនកាច ចរិកគាត់លេងសើចហ្នឹងខ្ញុំធ្លាប់ឃើញគាត់ម្តងណា ខ្ញុំមិនដែលនៅជិតទេ តែដូចថាគាត់ចុះមកប្រជាជនអីចឹង ថាគាត់ប្រុសយកអីមកឲ្យហូបចឹងថាម៉ោង១២មកដល់គឺមកដល់ហើយ ដឹកផ្លែឈើយកមកឲ្យហូបនំចំណីអី មានត្រីខអីចឹងណាស់ ។

ប្រុញៈ ចឹងគាត់មានយកអាហារមកច្រើនទេ?

ភីៈ គាត់ដឹកយកមកដឹង តែសំដីសំដៅគាត់ម៉េចៗទៅមុខទៀតខ្ញុំមិននៅជិតផង គ្រាន់ឃើញមួយភ្លែតៗចឹងដូចជាអត់អី ។

ប្រុញៈ ចឹងអ្នកនៅហ្នឹងស្រឡាញ់តាម៉ុកដែរ?

ភីៈ ចុះមានអី គាត់មិនមែនទៅធ្វើអីគាត់ ។

ប្រុញៈ គាត់ដឹកនាំទ័ពនៅហ្នឹងតែម្តងឬមួយយ៉ាងម៉េច?

ភីៈ គាត់សមរភូមិគាត់ដឹកនាំនៅហ្នឹងដឹង ខ្ញុំមិនសូវដឹងដែរ ព្រោះខ្ញុំនៅក្រោយណាស់ ហើយគាត់មិនមែននៅជាប់ជាមួយប្រជាជនដែរ គាត់នៅរបស់គាត់ផ្សេងកន្លែងគាត់ ខ្ញុំជួបពេលគាត់យកស្ករៗមកឲ្យហូបខ្ញុំជួប ។

ប្រុញៈ ជួបញឹកដែរ?

ភីៈ ចាស!ជួបដូចគាត់ដឹកឪឡឹកមកហ្នឹង ឡានយើងអ៊ីណូរបស់ថៃនោះ ដឹកយកមកហើយ មកដល់ហៅតាមកងហ្នឹងយកទៅ ចែកចឹងទៅ ។

ប្រុញៈ តាម៉ុក ភាគច្រើនគាត់និយាយរឿងអីគេ?

ភីៈ និយាយរួមខ្ញុំមិនហ៊ានទៅជិតផងអ្នកធំ យើងមិនសូវទំនាក់ទំនងទេ បើថាគ្នាឯងបេះតែនេះទៅ ថាគាត់មកចឹងគ្រាន់បានអង្គុយស្តាប់អី គាត់និយាយអីហ្នឹង បើឲ្យទៅសួរនាំផ្ទាល់តែម្តងមិនហ៊ាន ។

ប្រុញៈ មានធ្លាប់ចាំថាគាត់និយាយអីខ្លះទេ?

ភីៈ អត់ចាំទេ កាលហ្នឹង ដូចថាគាត់គ្រាន់មកជួបអ្នកទទួលខុសត្រូវអីចឹង អញយកនេះមកឲ្យហងស៊ី មីនេះ មីនោះអីចឹងទៅមិត្តឯងចឹងទៅក៏ហើយយើងដើរចេញយើងមិននៅជិតទេ ។

ប្រុញៈ ចឹងគាត់មាននិយាយវាយជាមួយខាងរដ្ឋាភិបាលអីទេ?

ភី៖ គាត់មិនដែលនិយាយទេ រឿងផ្ទៃក្នុងខ្ញុំមិនសូវដឹងទេ ដូចខ្ញុំថាអ្នករាយរងយើងមិនហ៊ានទៅជិតណាស់ ។

វណ្ណៈ៖ ចឹងកាលមីងមកនៅ៨០៨ហ្នឹង មីងឃើញតាម៉ុក មួយឬមានឃើញ សុន សេន ដែរឬឃើញពីណាផ្សេងទៀតដែរ ដែលនៅ៨០៨ហ្នឹង?

ភី៖ មកនៅ៨០៨ហ្នឹង អត់ទេ តា១ទៅលិចបើមកនៅបីមុំអាហ្នឹងខ្ញុំឃើញតា១ហ្នឹង គេហៅតាខៀវ តាសុន សេន ហ្នឹង ។

ប្រុញ៖ ហ្នឹងមកមុំបី?

ភី៖ ចាស!កាលនៅមុំបី ។

ប្រុញ៖ មកនៅមុំបីហ្នឹងឆ្នាំណាអ៊ី?

ភី៖ មកនៅឆ្នាំ៨១ហ្នឹង ។

ប្រុញ៖ ឃើញ សុន សេន ហើយបានឃើញពីណាទៀត?

ភី៖ ឃើញតែតាហ្នឹងមួយគាត់នៅហ្នឹង គេហៅតាខៀវ១ហ្នឹង តាសុន សេន ហ្នឹង ។

ប្រុញ៖ មនុស្សគាត់យ៉ាងម៉េចដែរ?

ភី៖ ឥឡូវគេហៅតាសុន សេន កាលខ្ញុំស្គាល់តែ តាខៀវ ទេ មាឌគាត់សធំ ចាស់ហើយកាលហ្នឹង កាលខ្ញុំជួបហ្នឹងគាត់ចាស់ហើយ គាត់ប្រជុំអីចឹងទៅអ្នកភ្លើងនៅចឹងអត់ដែលចោលទេអ្នកភ្លើង ដុតហ៊ុយជាប់ចឹង ។

ប្រុញ៖ គាត់ប្រជុំរឿងអីគេ?

ភី៖ គាត់ប្រជុំរឿងយើងរស់នៅក្នុងសង្គមចឹង ដំណាតទៅមុខយើងរស់នៅថ្នាក់តែមួយចឹង ថ្នាក់តែមួយដូចថា គាត់និយាយរឿងដល់យើងហ្នឹងមកដល់បច្ចុប្បន្នខាងមុខហ្នឹង យើងនៅក្នុងថ្នាក់តែមួយចឹង គាត់អប់រំយើងឲ្យយើងយល់ យើងរបៀបរបបតែមួយ យើងរស់ទៅមុខហ្នឹងដូចថាវាថ្នាក់តែមួយចឹង ហើយគាត់ហ្នឹងមិនបានរស់នៅប៉ុន្មានទេ ព្រោះគាត់ចាស់ហើយ ។

ប្រុញ៖ គាត់និយាយចឹង?

ភី៖ ចាស ។

ប្រុញ៖ គាត់អប់រំយើង?

ភី៖ គាត់អប់រំយើងឲ្យយើងយល់ឲ្យហើយ កុំឲ្យកាលណាយើងមកនៅភាគីខាងនេះមួយខាងនេះមួយ យើងមកប្រេបាច់ចូលគ្នាកុំឲ្យយើងប្រឡំបុល ឈ្លូសគ្នា ចឹងគាត់អប់រំផ្នែកនយោបាយឲ្យយើងយល់មុនឲ្យហើយចឹង ។

ប្រុញ៖ នៅក្នុងឆ្នាំណាឆ្នាំ៧១គាត់និយាយ?

ភី: អត់ទេ ឆ្នាំ៧៨ឆ្នាំ៧៣អះ!៨៣ ។

ប្រុញ: ចឹង៨៣?

ភី: ចាស!៨៣យើងនៅមុំបី គាត់ហៅទៅរៀនចឹង ហៅប្រជាជនទៅរៀនសន្និបាតម្តងចឹង ។

ប្រុញ: ធ្វើញឹកទេ សន្និបាតគេ?

ភី: មិនសូវញឹកទេ យូរៗម្តងមួយឆ្នាំអីទៅគាត់គាត់ពីរដង សន្និបាតរួមចឹងប្រជាជនទាំងអស់ ។

ប្រុញ: ចឹងមុនគាត់និយាយថាចង់ឲ្យរួបរួមគ្នាចឹង គាត់ធ្លាប់និយាយពីការវាយប្រឆាំងអីយ៉ាងម៉េច?

ភី: គាត់មិនដែលនិយាយទេ គាត់មិនដែលនិយាយប្រហាពីខាងនេះ គាត់មិនដែលនិយាយទេ គាត់អប់រំពន្យល់យើងរឿងទិសដៅត្រូវទៅខាងមុខទៀតចឹង តែពួកខ្ញុំគាត់អប់រំយើងស្តាប់ទៅ យើងចេះតែចាំមើល ចាំមើលថា គាត់និយាយហ្នឹងដូចមាត់គាត់ថាមែនអត់ ដល់ពេលមក ដល់ពេលមានសមាហរណ៍កម្មនេះគាត់មែន វាដូចគាត់ថាមែន ។

ប្រុញ: គាត់អប់រំឲ្យរស់នៅជាមួយគ្នា?

ភី: ចាស!រស់នៅឲ្យវាត្រូវគ្នា ឲ្យយើងយល់ឲ្យហើយ ក្រែងលោយើងផ្តាច់ខ្លួនតឹបមកហើយទៅ ទ័ពខាងនោះមកវាយខាងនេះ យើងវាអត់យល់ណាស់ ដល់ចឹងគាត់អប់ថា យើងហ្នឹងខ្មែរតែ មួយ យើងកុំអាកហុតឈាមខ្មែរតែមួយពូជសាសតែមួយ យើងត្រូវសាមគ្គីគ្នា ជួយគ្នាឲ្យ បានល្អកសាងប្រទេសអីចឹង អប់រំផ្លូវល្អ ដល់ហើយខ្ញុំចេះចាំមើលដល់ហើយមែន ដូចគាត់ និយាយមែន ។

ប្រុញ: ចឹងពេលគាត់អប់រំចឹង មុនដំបូងគេជឿគាត់ដែលទេ?

ភី: ជឿ ។

ប្រុញ: ជឿដែរ?

ភី: ចាស!ជឿ ព្រោះយើងតាមដានមើល តាមមើលពុទ្ធទំនាយមួយដំណាក់ៗចឹងមកវាអត់មាន ខុសទេ តាមគាត់អប់រំចឹង ។

ប្រុញ: ដល់ពេលគាត់អប់រំរយៈពេលបានប៉ុន្មានបានមានការផ្តាច់ខ្លួន?

ភី: កាលហ្នឹងបានប៉ុន្មាន បានមួយឆ្នាំអី បានយើងកើតកុលយុគហ្នឹងបណ្តោយ ។

ប្រុញ: កើតកុលយុគយ៉ាងម៉េច?

ភី: កើតកុលយុគដែលយើងចាប់ដៃគ្នា ចុះចូលជាមួយគ្នា យើងឈប់ច្បាំងគ្នា ។

ប្រុញ: ឆ្នាំណា?

ភី: មើលឆ្នាំប៉ុន្មានទេ ខ្ញុំភ្លេចខ្ញុំទៅទំនប់ដាច់នេះ ពួកខ្ញុំនៅនេះ មើលចុះពីលើភ្នំមកខ្ញុំនៅស្រះឈូក នេះ នៅត្រពាំងប្រិយ ដល់ពេលយួនមកដល់អន្លង់វែងនេះ ពួកខ្ញុំឡើងទៅនៅមាត់ភ្នំ មាត់ភ្នំ

ដល់ពេលយួនទៅវិញ ខ្ញុំចុះមកបានគេឲ្យខ្ញុំទៅនៅទំនប់ដាច់ ដល់នៅទំនប់ដាច់យើងចរចារគ្នាហ្នឹងនៅទំនប់ដាច់ហ្នឹង ។

ប្រុញៈ កាលហ្នឹង៩០ជាងហើយ?

ភីៈ កាលហ្នឹង៩០ប៉ុន្មានទេ ៩០ជាងតែមិនដឹង៩០ប៉ុន្មាន កាលហ្នឹង ។

ប្រុញៈ ចឹងកាលហ្នឹងពីណាគេជាអ្នកតំណាងអ្នកដែលនៅមុំបីហ្នឹងមកចរចារ មកចាប់ដៃគ្នា?

ភីៈ កាលហ្នឹងមិនថាពីណាពីណីទេ ទៅតាមគេតែម្ដង ប្រជាជនគេឲ្យទៅៗដល់ហើយខ្ញុំទៅដល់ទំនប់ដាច់ដល់ហើយគេថាទាហានខេមៈមក ទាហានខេមៈមកនៅទៅយើងនៅចឹងគាត់ចូលមកគាត់សួរពីនេះពីនោះអីចឹង យើងនិយាយធម្មតា ។

ប្រុញៈ ខាងទាហានខេមៈមកសួរ?

ភីៈ ចាស! ហើយគាត់ហ្នឹងក៏ធម្មតាទៅ ។

ប្រុញៈ គាត់ឈ្មោះអីគេ?

ភីៈ អត់ស្គាល់ឈ្មោះ មានពីណាស្គាល់ ។

ប្រុញៈ ក្រែងថាមានតំណាងមក?

ភីៈ អត់ទេ! ចូលមកចឹងយើងអត់មានស្គាល់ទេទ័ព ហើយក្នុងចិត្តចេះតែខ្លាចណាស់ ខ្លាចគេបាញ់អី ដល់មកនិយាយត្រូវរ៉ូគ្នាទៅក៏ធម្មតា ហើយពួៗហ្នឹងគាត់នៅកន្លែងគាត់ទៅ នៅជិវិគាត់ធ្វើការចឹងទៅពួកខ្ញុំប្រជាជននៅមុំចឹងទៅណាស់ ។

ប្រុញៈ ខ្ញុំចាប់អារម្មណ៍យួនមកញ៉ែមកជីដងអីចឹង មុនឆ្នាំ៧៥មានរឿងចឹងកើតឡើងដែរ?

ភីៈ ៧៥អត់ទេ ។

ប្រុញៈ មុនឆ្នាំ៧៥?

ភីៈ មុនឆ្នាំ៧៥អត់មានទេ មុំខ្ញុំអត់មានយួននៅទេ ។

ប្រុញៈ ចឹងអត់មានយួនទេ?

ភីៈ ទើបឆ្នាំ៧៩ ដេលយួនចូលស្រុកហ្នឹងបណ្ដោយខ្ញុំទៅផ្ទះវិញនោះណាស់ ហ្នឹងមានខ្ញុំឃើញខ្ញុំទៅនៅបានប្រហែលជាកន្លះខែ ថាកន្លះខែចុះ ខ្ញុំចូលព្រៃមកវិញបាត់មក ។

ប្រុញៈ យួនវាទៅដោយសារ?

ភីៈ ចុះទ័ពវា ទ័ពនៅតាមភូមិតាមអីចឹងណាស់ ។

ប្រុញៈ យើងឃើញចឹងអាចខ្លាចចឹងដោយសារយួនវាយចូលភ្នំពេញហ្នឹងតែម្ដងឬយ៉ាងម៉េច?

ភីៈ អត់ទេ យួនចូលទូទាំងប្រទេសតែម្ដង ។

ប្រុញៈ តែអឹថា រត់ចូលព្រៃដោយសារយួនមករញ៉េរញ៉ៃកូនចៅស្រីៗអីចឹង?

ភី: ចាស! អាហ្នឹងយើងចេះតែខ្វាចទៅ ។

ប្រុញ: តែអាហ្នឹងខ្វាចដោយសារយួនវាយចូលឆ្នាំ៧៩ហ្នឹងផង?

ភី: ចាស ។

ប្រុញ: ចឹងឆ្នាំ៧៩មកទៀតហ្នឹងអត់មានដេលជួបជាមួយយួនវាយគ្នាទេ?

ភី: អត់ដែលជួបទេខ្ញុំ ខ្ញុំនារីអត់ដែលប្រទះទេ គេឲ្យនៅក្នុងព្រៃដើរជីកក្ដួចជីកដំឡូងធម្មតាហ្នឹង កាលជំនាន់ហ្នឹង យកមកលាយជាមួយអង្ករអីទៅដំឡូងហ្នឹង កាលនៅក្នុងព្រៃហ្នឹង ពូៗបានគេមកសមរភូមិខាងក្នុង មីងៗនៅតែក្នុងព្រៃ ទើបមកយើង៨១បានមកឡើងភ្នំដងរែកហ្នឹង ។

ប្រុញ: ចឹងពេលប្រជុំហ្នឹងគេមាននិយាយរឿងយួនយ៉ាងម៉េចទេ?

ភី: ឥឡូវប្ដូជំនាន់ ។

ប្រុញ: ជំនាន់៨០ជាងមក?

ភី: អត់ទេ មិនដែលនិយាយអីផង ។

ប្រុញ: ចឹងឆ្នាំណាបានមកសុខសាន្តពេញលេញតែម្ដងឆ្នាំណា?

ភី: សុខសាន្តយើង៩០ប៉ុន្មាននេះហ្នឹង ។

ប្រុញ: ចឹងចាប់តាំងពីចាប់ដៃគ្នាហើយ?

ភី: ចាស! សុខរហូតមិនដែលមានរឿងអីទេ ។

ប្រុញ: ចាប់ដៃគ្នាហើយអ៊ឹមកនៅណាវិញ?

ភី: ខ្ញុំនៅទំនប់ដាច់ដល់ហើយ នៅទំនប់ដាច់ត្រូវរ៉ូវគ្នាមើលដើមខែ៤ចុងខែ៣ចេញពីនេះទៅមិនទៅនៅហ្នឹង ដល់ចូលឆ្នាំហើយខ្ញុំមកនៅផ្ទះខ្ញុំវិញ មកនៅនេះវិញរហូតដល់រាល់ថ្ងៃហ្នឹង ។

ប្រុញ: ចឹងនៅនេះមានសុវត្ថិភាពល្អ?

ភី: អត់អីទេ ។

ប្រុញ: សុទ្ធបងប្អូនស្គាល់ចិត្តស្និទ្ធគ្នាទាំងអស់?

ភី: ចាស! រស់នៅជាមួយគ្នាដូចថាស៊ីអត់ស៊ីឃ្លានជាមួយគ្នាចឹង ។

ប្រុញ: នៅនេះសុទ្ធខ្មែរសុទ្ធ?

ភី: នេះខ្មែរសុទ្ធ ខ្មែរហ្នឹងគ្រាន់ពួកខ្ញុំនៅនេះចាស់ កម្លាំងយើងពីមុនមកច្រើនហ្នឹង ពេលផ្ដាច់ខ្លួនខ្លះគេទៅស្រុកអស់ ខ្ញុំអ្នកកំណើតនេះនៅតែ២០គ្រួសារទេ កំណើតយើងតស៊ូនៅតែ២០គ្រួក្រៅពីហ្នឹងសុទ្ធតែអ្នកចំណូលអ្នកមកពីក្នុងវិញ នៅនេះមានតែ២០គ្រួទេ កំណើតកើតជាជំនាន់ហ្នឹងមកនោះ ។

ប្រុញ: ចឹងកាលយើងចូលព្រៃហ្នឹងមានធ្វើបុណ្យទានតាមប្រពៃណីទេ សាសនាយើងទេ?

ភី: យើងនៅ តែយើងមិនធ្វើបុណ្យទ្រង់ទ្រាយទេ ដូចថាផ្ទះចិន ពេលចូលឆ្នាំចិនទៅរដ្ឋាភិបាលហ្នឹងចែកត្រីខ ចែកអន្ទក់រដំណើមអីចិនមកណាស់ ហើយយើងសែននៅផ្ទះស្លាត់ចិនទៅ នឹកដីដូនជីតាយើងធម្មតាចិន តែយើងអត់មានវត្ត ដល់ពេលអត់វត្តយើងធ្វើតាមផ្ទះធម្មតា ។

ប្រុញៈ ចឹងពេលនៅក្នុងព្រៃឆ្នាំ៨០ជាងអី?

ភី: ហ្នឹងអត់មានស្អីធ្វើទេ ។

ប្រុញៈ គេមិនឲ្យយើងធ្វើ?

ភី: អត់មានអ្នកណាថាមិនឲ្យយើងធ្វើទេ តែយើងគ្មានអីធ្វើតែម្តង យើងដាច់រយៈពីផ្ទះនៅតែក្នុងព្រៃហ្នឹង ដូចថាយើងពួនឲ្យតែសុខ ទំរាំយើងរករយៈឃើញបានយើងឡើងមកលើភ្នំនេះអាហ្នឹងបានមានអីហូបគ្រប់គ្រាន់ហើយ ខោអាវស្លៀកពាក់គ្រប់គ្រាន់បរបូរណ៍តែម្តង ។

ប្រុញៈ ចឹងកាលសម័យហ្នឹងមានចាប់ខ្មាំងអីទៀតទេ?

ភី: អត់មានចាប់ទេ ។

ប្រុញៈ ចឹងអត់មានទេ?

ភី: ចាស ។

ប្រុញៈ ចឹងអ៊ីរាល់ថ្ងៃនេះ អ៊ីមានដឹងពីសាលាក្តីគេជំនុំជម្រះមេដឹកនាំខ្មែរក្រហមធំៗ រាល់ថ្ងៃនេះគេកំពង់កាត់មានឈ្មោះ នួន ជា លេខាបក្សអនុលេខាបក្សសម័យហ្នឹង?

ភី: មិនដឹងយ៉ាងម៉េចខ្ញុំមិនសូវដឹងដែរ ។

ប្រុញៈ អ៊ីមានដឹងពីតុលាការហ្នឹងទេ ខាងតុលាការគេធ្លាប់មកនាំប្រជាជនទៅមើលដែលតើ?

ភី: អត់ទេ មិនដែលឃើញទេ ។

ប្រុញៈ អត់ដែលសោះតែម្តង?

ភី: ចាស!អត់ដែលសោះតែម្តង ។

ប្រុញៈ ចឹងអ៊ីមានដែលស្តាប់តាមវិទ្យុទេ?

ភី: វិទ្យុស្តាប់ពុតែថាឲ្យទៅដល់កន្លែងអីហ្នឹងហ្នឹងមិនដឹងទេ ។

ប្រុញៈ អត់ដែលដឹង?

ភី: អត់ដែលសោះ ខ្ញុំមួយជិនារនេះអត់ដែលទេ វិទ្យុមានស្តាប់ទៅបើអត់ក៏អត់ដែលហ្នឹង ។

ប្រុញៈ ចឹងអ៊ីយល់ថាការកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗមួយចំនួនដែលអ៊ីបានស្តាប់ហ្នឹង តើអ៊ីយល់យ៉ាងម៉េចដែរ ថាមានយុត្តិធម៌ទេ ឬមួយអត់មានយុត្តិធម៌ ចំពោះអ៊ី យ៉ាងម៉េចដែលបានដឹងកន្លងមកហ្នឹង?

ភីៈ ទេ តាមខ្ញុំរស់នៅជំនាន់ហ្នឹង ខ្ញុំថាទៅក្រែងលោកគាត់មិនជឿអីម៉េច ព្រោះរឿងពាក្យចាមអារាម តែងតែគេនិយាយថា ខ្មែរក្រហមកាប់សម្លាប់ធ្វើបាបអី ចំពោះមេដឹកនាំនៅខាងលើៗ គាត់អត់មានធ្វើចឹងទេ ប៉ុនអាខាងក្រោម អាហ្នឹងគេទៅឆ្វេងទៅស្តាំរបស់គេ គំនិតគេតែម្តង ឧទាហរណ៍ថា ហ៊ុន សែន ចឹងគាត់ដឹកនាំ ហ៊ុន សែន គាត់អត់មានធ្វើអីរាល់ថ្ងៃ អ្នកនៅខាងក្រោមហ្នឹងគឺអំណាចវាបុគ្គលវា វាធ្វើបាបចេះមួយចុះមួយ អាហ្នឹងជារឿងរបស់គេណា បើរឿងខាងលើដឹកនាំដូចវាអត់មានធ្វើដល់ម្ល៉ឹងទេ ពេលខ្ញុំធ្លាប់រស់នៅពេលសន្តិបាតម្តងៗអី ខ្ញុំតាមដែលខ្ញុំរស់នៅប៉ុន្មានឆ្នាំហ្នឹងដូចអត់មានអី តែមកខាងក្រោមនេះខ្ញុំអត់មានថាទេ ។

វណ្ណៈ ចឹងកាលអ៊ីរស់នៅសម័យបីឆ្នាំ តើអ៊ីមានដឹងថាកម្មាភិបាលមួយចំនួនគណៈតំបន់ គណៈស្រុក មានគេផ្លាស់ប្តូរនិងចាប់ខ្លួនអី កាលហ្នឹងមានដែលអត់អ៊ី?

ភីៈ រឿងម៉ាជំនាន់ហ្នឹងខ្ញុំអត់សូវដឹងដែរ ព្រោះគេលាក់ការណ៍គេមិនសូវឲ្យយើងដឹង គ្រាន់តែបញ្ជូនទៅណាមកដោះដូរយ៉ាងម៉េចខ្ញុំអត់ដឹង ដឹងតែអ្នកថ្មីតែម្តង ស្គាល់តែអ្នកថ្មីតែម្តង ។

វណ្ណៈ ចឹងអ៊ីមានបានដឹងថា ប្រជាជននៅតាមសហករណ៍គាត់ មិនមានការហូបចុកគ្រប់គ្រាន់និងមានប្រជាជន១៧មេសាត្រូវបានគេយកទៅសម្លាប់ចោល អ៊ីមានបានដឹងឬអ៊ីមានបានឃើញឬយ៉ាងម៉េចដែរ?

ភីៈ ហ្នឹងបើខ្ញុំនៅភូមិខ្ញុំតែម្តង ខ្ញុំមិនទាន់ចេញមកចូលអង្គភាពដេរនេះ ខ្ញុំនៅមួយរយៈប៉ុន្មានឆ្នាំហ្នឹង កាលហ្នឹងខ្ញុំដឹង កាលហ្នឹងយើងមិនដាច់ភ្នំពេញ ហើយយកប្រជាជន១៧មេសាយកទៅផ្ញើរតាមសហករណ៍ ដល់ហើយសហករណ៍មួយៗ ដូចជាសហករណ៍ខ្ញុំនៅភូមិខ្ញុំហ្នឹង អត់មានអីទេ ហូបចុកដូចជាប្រជាជនយើងធម្មតាតែម្តង ។

ប្រុញៈ បាទ ។

ភីៈ ហើយធ្វើស្រែចម្ការ គាស់គល់អីជាមួយប្រជាជនយើងធម្មតា អត់មានធ្វើបាបចេះចុះអីទេ អាហ្នឹងកន្លែងខ្ញុំនេះទេ ។

ប្រុញៈ បាទ ។

ភីៈ បើកន្លែងផ្សេងខ្ញុំមិនបានដឹងដែលទេ តែកន្លែងខ្ញុំ ខ្ញុំឃើញចឹងឯង ។

ប្រុញៈ ចឹងឧទាហរណ៍បើគំនិតអ៊ីផ្ទាល់ ឧទាហរណ៍ជនជាប់ចោទរាល់ថ្ងៃហ្នឹង ឧទាហរណ៍ថា មានមេធាវី គេតែងតាំងឲ្យគាត់ការពារជនជាប់ចោទចឹង ហើយមេធាវីហ្នឹង គាត់ជាអតីតជនរងគ្រោះនៅក្នុងសម័យហ្នឹងដែលចឹង តើសម្រាប់អ៊ីគិតថា មេធាវីហ្នឹងមានគំនិតគលម្បៀងណាមួយដែលអាចធ្វើឲ្យការពារជនជាប់ចោទហ្នឹងអត់មានអស់ពីចិត្ត ចឹងអ៊ីគិតយ៉ាងម៉េចដែរ?

ភីៈ ខ្ញុំមិនដឹងគិតយ៉ាងម៉េចទេ ខ្ញុំមិនសូវយល់ ។

ប្រុញៈ ចឹងសួរខ្ញីថា ជនរងគ្រោះ គាត់ជាជនរងគ្រោះដោយសាររបបហ្នឹងចឹង ឥឡូវគាត់ក្លាយជាមេធាវីការពារឲ្យជនជាប់ចោទហ្នឹង ចឹងគំនិតអ៊ីគិតថា មេធាវីហ្នឹងអាចការពារជនជាប់ចោទឲ្យមានប្រសិទ្ធភាពដែលទេ?

ភីៈ ខ្ញុំដូចជាមិនសូវបានស្តាប់ទៀតទាត់ចឹង ដូចចឹងតាមដានរឿងសំណុំឯកសារដែលគាត់និយាយហ្នឹងមិនបានយល់ ដល់ចឹងមិនហ៊ានឆ្លើយដែរ ។

វណ្ណៈៈ ចឹងអាហ្នឹងយើងនិយាយតាមផ្លូវច្បាប់ ឥឡូវយើងនិយាយសមញ្ញាញថា មេធាវីហ្នឹងកន្លងមកគាត់ជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហមហ្នឹង គាត់ត្រូវបានគេធ្វើបាបអត់ឃ្លាន តែមកដល់ឥឡូវស្រុកយើងមានសន្តិភាព មានតុលាការត្រឹមត្រូវទៅគាត់ក្លាយខ្លួនជាមេធាវី ហើយគាត់ទៅការពារឲ្យអ្នកដែលបានធ្វើបាបគាត់ ឧទាហរណ៍ដូចជាលោក ខៀវ សំផន នួន ជា ចឹង គាត់ទៅការពារឲ្យអ្នកទាំងហ្នឹង មេធាវីហ្នឹងនៅក្រោមរបបអ្នកទាំងហ្នឹង ចឹងអ៊ីគិតថា ជនរងគ្រោះទៅការពារឲ្យអ្នកដែលធ្លាប់ធ្វើបាបខ្លួនពីមុនមកចឹង ចឹងការពារក្តីហ្នឹងវាអាចមានប្រសិទ្ធភាពដែលអត់ មានភាពលម្អៀងឬមានភាពយុត្តិធម៌ដែលអត់ នេះជាយោបល់ជាគំនិតអ៊ីគិត តើឲ្យជនរងគ្រោះជាមេធាវីទៅការពារជនជាប់ចោទ ដែលធ្លាប់ប្រព្រឹត្តិអំពើមកលើខ្លួនហ្នឹង គិតថា មានយុត្តិធម៌ដែលអត់ឬអាចគិតថាមេធាវីហ្នឹងការពារទៅវាមានលម្អៀងទៅខាងណាមួយអ៊ីចឹង ជាគំនិតរបស់អ៊ី គិតថាមេធាវីហ្នឹងការពារទៅវាមានលម្អៀងឬគ្មានលម្អៀង?

ភីៈ មិនយល់ដែរ ។

ប្រុញៈ បើនិយាយឲ្យសមញ្ញាញទៅដូចខ្ញុំមានកូនមួយអ៊ីចឹង ហើយកូនខ្ញុំក្លាយទៅជាមេធាវីអ៊ីចឹង តែខ្ញុំនេះត្រូវបានគេសម្លាប់នៅក្នុងសម័យខ្មែរក្រហមអ៊ីចឹង ឧទាហរណ៍ ចឹងកូនខ្ញុំនេះក្លាយទៅជាមេធាវីហើយ ប៉ុន្តែគេចាត់តាំងឲ្យគាត់មកការពារជួយជនជាប់ចោទដែលធ្លាប់សម្លាប់ឪចឹងសួរថា តើកូនខ្ញុំដែលក្លាយទៅជាមេធាវីហ្នឹង បម្រើការងារឲ្យជនជាប់ចោទហ្នឹងមានប្រសិទ្ធភាពដែលអត់ មានភាពលម្អៀងអត់ ព្រោះអ៊ីឪពុកខ្លួនហ្នឹងត្រូវបានគេសម្លាប់នៅក្នុងរបបបុគ្គលហ្នឹងចឹង?

ភីៈ និយាយរួមទៅគាត់មិនមានលម្អៀងទេ ។

ប្រុញៈ ចឹងយ៉ាងម៉េចបានជាអ៊ីគិតថា គាត់មិនមានលម្អៀង?

ភីៈ បើគាត់លម្អៀងគាត់មិនមែនហ៊ានចេញមុខទៅអះអាងធានាបុគ្គលហ្នឹងដែលបានធ្វើអំពើអាក្រកពីមុនមក គាត់យល់ច្បាស់ហើយបានជាគាត់ហ៊ានមុខគាត់ទៅអះអាង ថាបុគ្គលហ្នឹងអត់មានយោយៅពីមុនមកអ៊ីចឹង អាហ្នឹងតាមគំនិតខ្ញុំទេ ។

វណ្ណៈ៖ បាទ! ចឹងខ្ញុំចង់បន្តបន្តិចទៀតទាក់ទងនឹងការអឺមករស់នៅមុំបី ចេញពីមុំបីទៅ៨០៨ ចឹងអឺបានចេញពីមុំបីមក៨០៨ហ្នឹងឆ្នាំណា?

ភីៈ ឆ្នាំ៨៤ ។

វណ្ណៈ៖ ចឹងអ្នកដែលមក៨០៨ហ្នឹង គ្រួសារគេឲ្យទៅសមរភូមិមុខ ទៅខេត្តកំពង់ចាមហើយប្រពន្ធនៅខាងក្រោយនេះគេឲ្យធ្វើអីខ្លះដែរ?

ភីៈ ប្រពន្ធនៅក្រោយបើយើងទំនេរប្រហែលជាមួយខែអីហ្នឹង គេបិតចំរូងម្នាក់១០០ដើម២០០ដើម ។

វណ្ណៈ៖ ក្នុងមួយថ្ងៃ?

ភីៈ អត់ទេ មួយខែ ៧០ ក្រៅពីហ្នឹងទំនេរហូបបាយហូបចុកធម្មតាចឹងទៅ ។

វណ្ណៈ៖ ចំរូងគេបិតរបៀបយ៉ាងម៉េច គេយកអីបិត?

ភីៈ គេយកដើមប្ញស្សីយើង ។

វណ្ណៈ៖ គេបិតយ៉ាងម៉េច?

ភីៈ ស្រួចប្រវែងមួយចំអាមហ្នឹងស្រួចចុងស្រួចគល់ទៅ គេពុះប៉ុនចង្កឹះណាស់ ។

វណ្ណៈ៖ ចឹងមីងកាលហ្នឹងមានបានជញ្ជូនគ្រាប់អីទេ?

ភីៈ អត់ទេ!អត់មានជញ្ជូនទេនៅផ្ទះ ថានៅផ្ទះធម្មតាអ្នកមានកូន អ្នកអត់កូនក៏នៅតែដាំបាយដាំអីធម្មតាចឹង នាំគ្នាព្រោកព្រាចគ្នាលេងចឹងទៅ ។

វណ្ណៈ៖ តែខ្ញុំបានជួបមីងៗខ្លះថា បើយើងមានកូនចៅធំៗគេបន្ទុរបន្ទាយ តែបើយើងទើបការហើយឆ្នាំ៨០-៨១ហ្នឹង នៅមានកម្លាំងគេឲ្យជួយជញ្ជូនគ្រាប់ចឹងមានមែនដែលអត់?

ភីៈ អាហ្នឹងនិយាយទៅវាដោយកន្លែង ដូចខ្ញុំនិយាយពីដើមមកចឹង អង្គភាពគេខ្លះតឹងចឹងទៅ អង្គភាពខ្លះគេធូរចឹង ដូចខ្ញុំនិយាយពីដើមមកវាមិនមែនទូទៅទេ អង្គភាពខ្ញុំកន្លែងវរសេនាធំខ្ញុំអត់អី ។

វណ្ណៈ៖ វរសេនាធំលេខប៉ុន្មាន?

ភីៈ វរសេនាធំអត់មានលេខអីទេ ។

វណ្ណៈ៖ ចឹងអង្គភាពមានលេខទេ?

ភីៈ អត់ ខ្ញុំនៅនារីទទួលខុសត្រូវហ្នឹង អង្គភាពនារីហ្នឹងឈ្មោះ យាយ វ៉ាន គេអត់មានដាក់លេខទេ ។

វណ្ណៈ៖ ចឹងអឺនៅ៨០៨រយៈពេលប៉ុន្មាន បានមានការផ្លាស់ប្តូរទៅណាទៀត?

ភី៖ អត់មានផ្លាស់ទេ នៅហ្នឹងទៅដល់ពេលយួនវាយដល់មើលចុះមកនេះ៩០ប៉ុន្មានទេ ៩១ឬ៩០ គត់ទេ ចុះមកនៅដីយើងហ្នឹង ។

វណ្ណៈ៖ បាទ ។

ភី៖ ចុះមកនៅហ្នឹងរហូតដល់ពេលយួនវាយ នៅអន្លង់វែងនេះ រត់ទៅនៅមាត់ភ្នំ យួនទៅវិញចុះមក នៅវិញដដែល នៅដល់រាល់ថ្ងៃហ្នឹងតែម្ដង ។

វណ្ណៈ៖ ចឹងបើតាមដឹងអ៊ីនិយាយមកត្រូវហើយ ។

ភី៖ ចាស ។

វណ្ណៈ៖ ប្រហែលជាឆ្នាំ១៩៩០ហ្នឹង តាម៉ុក គាត់ឈូសផ្លូវអីហ្នឹង?

ភី៖ ចាស ។

វណ្ណៈ៖ ឈូតចុះពីលើភ្នំដើម្បីនាំប្រជាជនដែលនៅស្រុកថៃអីហ្នឹង ឲ្យមកនៅតាមភូមិ?

ភី៖ ចាស!ឲ្យមកនៅនេះវិញ ។

វណ្ណៈ៖ ចឹងមានខ្លះនៅ១០៥ខ្លះនៅ៨៩អីចឹង?

ភី៖ ចាស ។

វណ្ណៈ៖ ចឹងភូមិនេះគេហៅភូមិលេខប៉ុន្មានដែរ?

ភី៖ អត់មានលេខគេហៅភូមិអូរស្វាយតែម្ដង ។

វណ្ណៈ៖ ចឹងភូមិអូរស្វាយ ឃុំអូរស្វាយា?

ភី៖ ចាស!ស្រុកត្រពាំងប្រាសាទ ។

វណ្ណៈ៖ ចឹងខុសពីកន្លែងផ្សេងៗខ្លះគេហៅភូមិ៨៩ខ្លះភូមិ១០៥ តែឥឡូវគេប្រែឈ្មោះខ្លះហើយ គេថាពីមុនគេដាក់លេខតាមកងពល?

ភី៖ ហ្នឹងហើយកងពលពីមុនមក ។

វណ្ណៈ៖ ចឹងនៅនេះមានកងពលពីណាគេ?

ភី៖ កាលមុននេះកងពល៨០១ ។

វណ្ណៈ៖ កងពល៨០១?

ភី៖ ចាស!ប៉ិនដល់ហើយគេអត់មានប្រើទេ អ្នកទទួលខុសត្រូវហ្នឹងកម្លាំងបែកគ្នាលិចកើតទៅដល់ នៅភូមិនេះគេដាក់អូរស្វាយតែម្ដង ។

វណ្ណៈ៖ តែនៅក្នុងកងពល៨០១?

ភី៖ ចាស ។

វណ្ណៈ៖ កងពល៨០១ពីណាគេគ្រប់គ្រង?

ភី: តា យន ។

វណ្ណៈ: ចឹងតាសារឿន?

ភី: ហ្នឹងហើយកងពលហ្នឹង វរសេនាធំតាយន កងពលតាសារឿន ។

វណ្ណៈ: ចឹងតាសារឿន គ្រប់គ្រងលើតាយន?

ភី: ចាស ។

វណ្ណៈ: ចឹងនៅហ្នឹង៨០១?

ភី: ចាស!៨០១ពីមុនដល់ពេលកម្ពាំងបែកខ្ញែកគេឈប់ហៅទៅ គេហៅភូមិអូរស្វាយវិញ ។

វណ្ណៈ: ចឹងអ៊ីចុះមកនៅអូរស្វាយហ្នឹងតែម្ដង?

ភី: ចាស ។

វណ្ណៈ: ទោះបីមានសង្គ្រាមខាងរដ្ឋាភិបាលវាយចុះឡើងក៏អ៊ីមកនៅហ្នឹងដដែល?

ភី: ក៏នៅមកនៅហ្នឹងដដែល ។

វណ្ណៈ: ចឹងគ្រាន់តែរត់ហើយមកនៅវិញ?

ភី: ចាស!កាលហ្នឹងរត់ទៅនៅទំនប់ដាច់ បកពីទំនប់ដាច់មកនៅហ្នឹងវិញ ព្រោះជង្រុកស្រូវនៅហ្នឹងយើងទៅណា ។

វណ្ណៈ: ចឹងដល់ក្រោយមកទៀតកម្លាំងខ្មែរក្រហមដូចគ្នាហ្នឹងណាស់ ក្រោយមកដូចជាចេះតែខ្វាចអ្នកនេះអ្នកនោះរួចហើយរត់ទៅចូលជាមួយខាងរដ្ឋាភិបាល មានការសង្ស័យគ្នារហូតដល់មានការសម្លាប់តាសុន សេន អ៊ីចឹងកាលហ្នឹងអ៊ីមានដឹងថា សភាពការណ៍យ៉ាងម៉េចដែលនៅពេលហ្នឹងមានដឹងថា ហេតុអ៊ីបានឈានដល់ការសម្លាប់អ៊ីចឹង?

ភី: អត់ដឹង ។

វណ្ណៈ: ចឹងពេលដែល សុន សេន ស្លាប់អ៊ីមានដឹងទេ?

ភី: អត់ដឹងដែរ ខ្ញុំអត់មានដឹងទេ ។

វណ្ណៈ: ចឹងពេលដែលតាម៉ុក ចាប់ ប៉ុល ពត កាត់ទោសអ៊ី គេមានអញ្ជើញអ៊ីឲ្យទៅមើលដែលអត់កាលហ្នឹង?

ភី: មិនស្គាល់មិនដឹងសោះ គេមិនឯាយឲ្យយើងទៅជិតទេ ។

វណ្ណៈ: ចឹងបើតាមខ្ញុំដឹងខ្លះ តាម៉ុក គាត់មានការបែងចែក គាត់មិនសូវទុកចិត្តអ្នករស់នៅត្រពាំងប្រាសាទទេ?

ភី: ចាស ។

វណ្ណៈ: ព្រោះខាងគាត់នៅខាងអន្លង់វែង ខាងបងយឹម ដាន់ណា យឹម ពឹម អ៊ី?

ភីៈ ចាស ។

វណ្ណៈ ខាងនេះខាងតាជាតិ ជុំ អីចឹង?

ភីៈ ចាស ។

វណ្ណៈ ហើយដល់ពេលកម្ទាំងនៅខាងនេះ ។

ភីៈ ខាងនេះនៅជាមួយតាសារឿន ខាងនោះតាម៉ុក ។

វណ្ណៈ ចឹងក្រោយពីសម្លាប់ សុន សេន ហើយ តាម៉ុក ហ្នឹងហៅតាសារឿន តាសាន យោសនាឲ្យចូលមក ដល់ហើយតាម៉ុក គាត់ចាប់ខ្លួនតាសារឿន តាអីហ្នឹង ពេលហ្នឹងអ៊ំដឹងទេ?

ភីៈ អត់ដឹងទេខ្ញុំ ។

វណ្ណៈ ចឹងអត់ដឹងដែរ?

ភីៈ ចាស!ខ្ញុំមិនសូវដឹងទេ និយាយរួមទៅរឿងការងារគេខ្ញុំនិយាយឲ្យខ្លី រឿងការងារខ្ញុំមិនដឹងតែម្តង ខ្ញុំគិតតែស្រែចម្ការតែម្តង ដល់ហើយគេថា ហកសភាពការណ៍អត់ស្រួលរៀបចំឥវ៉ាន់ត្រៀម ជម្លៀសត្រៀមទៅជាមួយគេតែម្តង អត់មានដឹងរឿងខាងលើ ។

វណ្ណៈ ចឹងកាលហ្នឹងអ៊ំមានដឹងថា ក្រោយពីប្រទេសចិនផ្តាច់ជំនួយ ខាងវៀតណាមដកទៅវិញតាម៉ុកកាប់ឈើលក់ឲ្យថៃអ៊ំមានដឹងទេចឹង?

ភីៈ អត់ដឹងទេ ។

វណ្ណៈ ចឹងនៅក្នុងពេលហ្នឹងទៀតមានការចរចារនៅប៉ារីសអី មានអ៊ុនតាក់ចូលមក ចឹងនៅតំបន់ហ្នឹងមានអ៊ុនតាក់ចូលមកដល់ដែលឬមួយអត់ទេ?

ភីៈ អត់មានទេ ។

វណ្ណៈ ចឹងនៅហ្នឹងឆ្នាំ១៩៩៣មិនបានបោះឆ្នោតទេ?

ភីៈ ឆ្នាំ៩៣ ។

វណ្ណៈ បោះឆ្នោតដំបូងគេបំផុត?

ភីៈ ៩៣បោះអីយើងនៅនេះ ផ្តាច់ខ្លួនហើយយើងមិនបោះឆ្នោត ។

វណ្ណៈ ផ្តាច់ខ្លួនហើយបានបោះអាហ្នឹងឆ្នាំ៩៨ហើយទេ?

ភីៈ ហ្នឹងហើយ ។

វណ្ណៈ តែបោះទីមួយកាលអ៊ុនតាក់?

ភីៈ អត់មានទេ ខ្ញុំបានបោះឆ្នោតពេលយើងផ្តាច់ខ្លួនទេ បើពីជំនាន់អ៊ុនតាក់អត់ដឹងទេ ។

វណ្ណៈ អ៊ំមានដឹងថា ពីណាខ្លះដែលបាននាំចូលជាមួយខាងរដ្ឋាភិបាល ស្គាល់អ្នកនាំឲ្យចូលជាមួយរដ្ឋាភិបាលដែរ?

ភី: និយាយរួមទៅអ្នកដែលនាំចូលជាមួយរដ្ឋាភិបាលកាលហ្នឹងខ្ញុំអត់ដឹង ដឹងតែទាហានមក មកដល់ពូៗសួរ អឹងងចូលខាងរដ្ឋាភិបាល អើយចូលក៏ចូលៗបើគេចូលទូទៅហើយ ត្រង់អ្នកដឹកនាំឲ្យចូលអត់មាន ចិត្តខ្លួនឯងដូចថាទៅតែម្តង ទ័ពមកដល់ឃុំលហើយ មានទៅណាទៀត។

វណ្ណៈ: ចឹងឆ្នាំណាអ៊ីដឹងថាមានសមាហរណ៍កម្មយើងបានសុខសាន្តយើងលែងមានសង្គ្រាមមកដល់សព្វថ្ងៃ ចឹងឆ្នាំណាមានសមាហរណ៍កម្មអ៊ីមានដឹងទេ ប្រហែលជាឆ្នាំ៩០ប៉ុន្មាន?

ភី: សមាហរណ៍កម្មកាលហ្នឹងនិយាយយើងមានសុខសាន្តត្រឹមយើងចាប់ដៃគ្នាហ្នឹង អត់មានវាយគ្នាទៀតផង។

វណ្ណៈ: តែក្នុងឆ្នាំណា?

ភី: មិនដឹងជាឆ្នាំណាទេ ខ្ញុំមិនបានចាំទេ។

វណ្ណៈ: ឆ្នាំអ៊ីបោះឆ្នោតលើកទី២ហ្នឹង?

ភី: បោះឆ្នោតលើកទី២ហ្នឹង។

វណ្ណៈ: បាទ!ហ្នឹងហើយនៅឆ្នាំ១៩៩៨។

ភី: ហ្នឹងហើយ៩៨អ៊ីមិនដឹង។

វណ្ណៈ: ចឹងដល់មានសមាហរណ៍កម្មចឹង អ៊ីគិតថា កាលអ៊ីនៅក្នុងព្រៃមកប្រៀបធៀបជាមួយរបបយើងសព្វថ្ងៃនេះ អ៊ីរស់នៅសព្វថ្ងៃនេះតើមានភាពខុសគ្នាដែលអត់?

ភី: ខុសតើ។

វណ្ណៈ: ខុសយ៉ាងម៉េចខ្លះ?

ភី: ខុសយើងរាល់ថ្ងៃនេះវាស្រួលវាសម្បូរសេដ្ឋកិច្ចអី វាជឿនលឿន ជំនាន់នោះយើងមានអីបានតែមួយហូបៗហ្នឹងឯង។

វណ្ណៈ: ចឹងមានរត់លួនកូនចៅមិនបានរៀនសូត្រ?

ភី: ចាស!អត់បានរៀនសូត្រ ឥឡូវនេះកូនយើងក៏បានរៀន ហើយយើងម៉ែហ្នឹងអ្នកណាអត់ចេះអក្សរគេឲ្យរៀនអក្ខរកម្មចឹងទៀតណាស់ វាស្រួលចឹងឯង។

វណ្ណៈ: ចឹងកូនអ៊ីរៀនបានដល់ថ្នាក់ណាខ្លះហើយ?

ភី: កូនខ្ញុំអាមួយនេះថ្នាក់ទី១២ អាមួយនោះទើបថ្នាក់ទី៨។

វណ្ណៈ: អ៊ីមានកូនទាំងអស់ប៉ុន្មាននាក់ដែរ?

ភី: មាន៥នាក់។

វណ្ណៈ: ហើយស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ភី: ស្រីពីរប្រុសបី។

វណ្ណៈ មានបានរៀបការខ្លះហើយនៅ?

ភី: រៀបការអស់បីនៅពីរ ។

វណ្ណៈ ចឹងបីនាក់ចេញពីបន្ទុកគ្រួសារហើយ?

ភី: ចាស! ចេញហើយ ។

វណ្ណៈ ចឹងប្ដីអ៊ីឈ្មោះអីគេ?

ភី: ទូន សេន ។

វណ្ណៈ ចឹងអ៊ី?

ភី: ខ្ញុំឈ្មោះ ភួង ភី ។

វណ្ណៈ អាយុប៉ុន្មានហើយអ៊ី?

ភី: ខ្ញុំ៥៥ ។

វណ្ណៈ ចឹងឪពុកអ៊ីឈ្មោះអីដែរ?

ភី: ឪពុកបង្កើតឈ្មោះ ភួង ភន ។

វណ្ណៈ ចឹងម្ដាយ?

ភី: ម្ដាយឈ្មោះ ជុំ ជុំ ។

វណ្ណៈ ហើយអ៊ីមានបងប្អូនប៉ុន្មាននាក់ដែរ?

ភី: បងប្អូនខ្ញុំនៅផ្ទះនោះមាន៧នាក់ ។

វណ្ណៈ ហើយរាល់ថ្ងៃនៅរស់ទាំងអស់គ្នាប្អូនមួយយ៉ាងម៉េច?

ភី: នៅរស់ទាំងអស់ ។

វណ្ណៈ ចឹងរស់ទាំង៧នាក់ហ្នឹង?

ភី: ចាស ។

វណ្ណៈ ហើយមកនៅនេះខ្លះដែលប្អូនមួយអត់ទេ?

ភី: អត់ទេ នៅនេះតែខ្ញុំមួយ ។

វណ្ណៈ ចឹង៧នាក់ហ្នឹងមានស្រីប៉ុន្មាននាក់ដែរ?

ភី: ៧នាក់ហ្នឹងមានស្រី៤ ។

វណ្ណៈ ចឹងបងទី១ឈ្មោះអីទៅ?

ភី: បងទី១ខ្ញុំ ។

វណ្ណៈ ចឹងទី២?

ភី: ទី២ប្អូនឈ្មោះ ភឿន ។

វណ្ណៈ ទី៣?

ភីៈ ទី៣ឈ្មោះ ភាព។

វណ្ណៈ ទី៤?

ភីៈ ទី៤ឈ្មោះ ភា។

វណ្ណៈ ទី៥?

ភីៈ ទី៥ឈ្មោះ ភូន។

វណ្ណៈ ទី៦?

ភីៈ ទី៦ឈ្មោះ ភីន។

វណ្ណៈ ទី៧?

ភីៈ ទី៧ឈ្មោះ ភិន។

ប្រុញៈ ចឹងនៅនេះគេហៅឃុំអីទេ?

ភីៈ ឃុំអូរស្វាយ។

វណ្ណៈ ចឹងដូចជារាល់ថ្ងៃហ្នឹងយើងរាប់អានជាមួយអ្នកជិតខាងអីយ៉ាងម៉េចដែរ?

ភីៈ ធម្មតា។

វណ្ណៈ ចឹងមានការខុសប្លែកគ្នាពីសម័យតស៊ូនិងសម័យនេះ មានភាពខុសប្លែកគ្នាទេ?

ភីៈ ពីសម័យតស៊ូនិងសម័យយើងឥឡូវនេះ អាហ្នឹងចំពោះខ្ញុំទេ បងប្អូនអ្នកដទៃទៀតមិនដឹង បើចំពោះខ្ញុំតស៊ូពីមុនមកយើងស៊ីអត់ស៊ីឃ្លានជាមួយគ្នា សាមគ្គីគ្នាល្អហើយសព្វថ្ងៃនេះក៏សាមគ្គីធម្មតា អត់មានទាស់ទែងខ្វែងគំនិតអី ដូចថាឈ្លូសប្រកែកគ្នាឲ្យមើលគ្នាមិនចំអីអត់មានទេ។

វណ្ណៈ ចឹងចំពោះគ្រួសារអ៊ីរាល់ថ្ងៃហ្នឹងមានទំនាក់ទំនងគ្នាល្អដែលឬមួយយ៉ាងម៉េច?

ភីៈ មានទំនាក់ទំនងល្អមិនដែលឈ្លូសផង កូនចៅខ្ញុំមិនដែលឈ្លូសគ្នាទេ។

វណ្ណៈ ចឹងដូចថា បើយើងចង់ធ្វើស្រែចម្ការអីចឹង តើមុននិងធ្វើស្រែចម្ការ តើអ៊ីមានដែលពិភាក្សាគ្នាជាមួយគ្រួសារអ៊ីដែលឬមួយអត់ទេ?

ភីៈ មានតើ។

វណ្ណៈ ចឹងពិភាក្សាច្រើនកើតមាននៅពេលណាទៅ?

ភីៈ ពេលយើងសម្រាកពេលយប់ពេលអីហ្នឹង។

វណ្ណៈ ចឹងថាឆ្នាំនេះយើងដាំអី ឆ្នាំក្រោយយើងដាំអីចឹង?

ភីៈ ចាស។

វណ្ណៈ ចឹងនៅក្នុងស្រុកភូមិនេះ ភាគច្រើនគេនាំគ្នាដាំអីទៅ?

ភី: នៅក្នុងភូមិនេះភាគច្រើនគេធ្វើស្រូវតែម្ដង ហើយដូចជាដំណាំសណ្ដែកល្ងអីជាបន្ទាប់បន្សំ ព្រោះដីវាមិនសូវមានទួល មានតែដីទំនាប ។

វណ្ណៈ: ចឹងផលដំណាំដែលធ្វើបានហ្នឹង ងាយស្រួលក្នុងការលក់ចេញដែលទេ?

ភី: មានអីស្រួលលក់ដែលហ្នឹង ។

វណ្ណៈ: ចឹងជីវភាពអ៊ំរាល់ថ្ងៃហ្នឹងជួបការលំបាកដែលឬមួយមិនអីទេ?

ភី: រាល់ថ្ងៃមិនអីទេ ។

វណ្ណៈ: ចឹងកាលសម័យបីឆ្នាំការហូបចុកយ៉ាងម៉េចដែល?

ភី: សម័យបីឆ្នាំ ចំពោះខ្លួនខ្ញុំអត់មានពិបាកហូប ។

វណ្ណៈ: ចឹងមុនសម័យបីឆ្នាំទៀត?

ភី: នៅផ្ទះពីដើមក៏អត់អីទេ ម៉ែឪខ្ញុំមធ្យមដែលពីដើម ។

វណ្ណៈ: ចឹងទំលាមទំលាប់ប្រពៃណីវិញ ការស្លៀកពាក់ពូដើមយើងមានហូរប្រមូងទៅវត្តអីចឹង កាលសម័យពីដើមមានទេ?

ភី: មាន ហើយមានមាសប្រាក់ដូចយើងឥឡូវដូចគ្នាហ្នឹង ។

វណ្ណៈ: ចឹងកាលសម័យបីឆ្នាំមានដែលអត់?

ភី: សម័យបីឆ្នាំយើងស្លៀកពាក់ខោអាវខ្មៅធម្មតា ។

វណ្ណៈ: ចឹងសម័យនេះយើងស្លៀកពាក់យ៉ាងម៉េចដែរ?

ភី: សម័យនេះយើងស្លៀកពាក់ច្រើន បើនិយាយរួម ខ្លួនខ្ញុំយើងស្លៀកពាក់ដូចចាស់ពីដើម តែក្មេងៗច្រើនស្លៀកពាក់បរទេសតែម្ដង ឃើញខោរ៉ីបអី ចាស់ពីដើមអត់មានទេ ។

វណ្ណៈ: ចឹងអ៊ំរៀបការនៅឆ្នាំណាដែរ?

ភី: ខ្ញុំរៀបការនៅឆ្នាំ៨៩ ។

វណ្ណៈ: ចឹងកាលហ្នឹងមានភ្លេងការដែលអត់?

ភី: មានយើងនៅលើភ្នំមានតើ ។

វណ្ណៈ: កាលឆ្នាំ៨១-៨២អត់ទាន់មានទេ ចឹងដល់៨៩មានហើយ?

ភី: ចាស ។

វណ្ណៈ: មានអាចារ្យមានលោកដែរ?

ភី: មាន! ចាស់ៗគាត់ចេះ តែលោកអត់មានទេ ។

វណ្ណៈ: ចឹងមានត្រឹមអាចារ្យ?

ភី: ចាស!មានត្រឹមអាចារ្យ ។

វណ្ណៈ៖	ចឹងមានភ្លេងមានអី?

ភី៖	មានភ្លេងការ ពូៗពីដើមគាត់នៅជាមួយម៉ែឪគាត់ ម៉ែឪគាត់ចេះចឹងទៅណាស់ ដល់ពេលមកយើងលើកុំផ្ញើទ្រអ៊ីខ្លួនឯងចឹងទៅ ។

វណ្ណៈ៖	ចឹងឥឡូវនៅក្នុងភូមិហ្នឹងមានវត្តមានអីទេ?

ភី៖	មានវត្ត ។

វណ្ណៈ៖	ចឹងវត្តហ្នឹងគេហៅវត្តអីគេ?

ភី៖	វត្តគិរីសុវណ្ណអូរស្វាយចឹង ។

វណ្ណៈ៖	ចឹងវត្តគិរីសុវណ្ណអូរស្វាយ?

ភី៖	ចាស ។

វណ្ណៈ៖	ចឹងអ៊ីរាល់ថ្ងៃកាន់ព្រះពុទ្ធសាសនាឬកាន់សាសនាផ្សេង?

ភី៖	អត់ទេ ខ្ញុំកាន់ព្រះពុទ្ធសាសនាយើងហ្នឹង ផ្សេងខ្ញុំមិនដែលស្គាល់ផង ។

វណ្ណៈ៖	ចឹងមីងយល់យ៉ាងណាដែរ មីងកាន់ព្រះពុទ្ធសាសនាហ្នឹងនាំឲ្យយើងប្រព្រឹត្តិអំពើល្អឬនាំឲ្យយើងប្រព្រឹត្តិអំពើអាក្រក់ សាសនាហ្នឹង?

ភី៖	ឲ្យយើងទៅផ្លូវល្អ ។

វណ្ណៈ៖	ចឹងសម័យបីឆ្នាំមានវត្តមានអ៊ាដែលសម័យបីឆ្នាំ?

ភី៖	អត់មានទេ ។

វណ្ណៈ៖	ចុះពីដើមវិញ?

ភី៖	ពីដើមមាន ។

វណ្ណៈ៖	ចឹងបញ្ហាដីធ្លី តើប្រជាជននៅក្នុងភូមិហ្នឹង មានប៉ះពាល់ជាមួយដីក្រុមហ៊ុនអីទេ មានរឹបអូសយកដែលឬមួយយ៉ាងម៉េច?

ភី៖	អត់មានទេ ដីក្រុមហ៊ុនគេកំណត់ដីក្រុមហ៊ុនហើយ ដីប្រជាជនកំណត់ដីប្រជាជនហើយចឹងណាស់ អត់មានប៉ះពាល់ទេ ។

វណ្ណៈ៖	ចឹងនៅក្នុងភូមិហ្នឹង បើសិនជាមានទាស់ទែងគ្នារហូតដល់មានការប្ដឹងផ្ដល់អី តើអ៊ីគិតថា អាចពឹងពាក់ច្បាប់បានដែលឬមួយយល់ថាច្បាប់និងមិនទាន់គ្រប់គ្រាន់ សម្រាប់បម្រើប្រជាជនទេ បើតាមអ៊ីយល់?

ភី៖	រាល់ថ្ងៃច្បាប់យើងមានប្រសិទ្ធភាពហ្នឹងហើយ យើងមានទំនាស់យើងដោះស្រាយទៅវាសុខស្រួលគ្នាតែម្ដង ។

វណ្ណៈ៖	ចឹងមានន័យថា ពឹងពាក់ច្បាប់បាន?

ភី: ចាស!ពីងពាក់ច្បាប់បាន អត់មានបញ្ហាអីទេ ។

វណ្ណៈ: ចឹងនៅក្នុងឃុំភូមិស្រុកយើងហ្នឹង មានខាងរោងចក្រឬក្រុមហ៊ុនអីគេមកដាក់វិនិយោគឬក៏យ៉ាង ម៉េចដែលអ៊ំ?

ភី: ទេ មិនទាន់មានទេ ។

វណ្ណៈ: ចឹងមិនទាន់មានទេ?

ភី: ចាស!មិនទាន់មានទេ មានតែរ៉ែធ្យូងមួយកន្លែងផ្លូវចូលមកហ្នឹង មានកន្លែងហ្នឹងមួយកន្លែង ហ្នឹង ។

វណ្ណៈ: ចឹងរឿងរ៉ាវកន្លងមកដែលអ៊ំធ្លាប់ឆ្លងកាត់ហ្នឹង អ៊ំមានដែលនិយាយប្រាប់កូនចៅឲ្យដឹងថា អ៊ំ ជួបការលំបាកយ៉ាងម៉េច ខំតស៊ូយ៉ាងម៉េចបានមកដល់ប៉ុណ្ណឹង អ៊ំមានដែលបាននិយាយប្រាប់ ទេ?

ភី: ខ្ញុំប្រាប់តើ ខ្ញុំខស្សាហ៍និយាយតើកូនខ្ញុំ ។

វណ្ណៈ: ចឹងកូនអ៊ំជឿដែរ?

ភី: ត្រង់ជឿមិនជឿខ្ញុំមិនដឹងវាទេ តែខ្ញុំប្រាប់ដែលហ្នឹង ម៉ែទំរាំចិញ្ចឹមពួកឯងធំៗហ្នឹងបីរត់ បីលូន មកទាល់សព្វថ្ងៃហ្នឹង ពេលខ្ញុំនិយាយទៅលើកូនអីទៅវាមិនសូវស្តាប់ ខ្ញុំលើកមូលហេតុកាលខ្ញុំ ជួបការលំបាកហ្នឹងប្រាប់វា ដូចថាឲ្យវានឹកឃើញម្តាយដែលខំ ដូចថាបង្កើតមកហើយខំបីរត់ បីលូន ខំចិញ្ចឹមវាបានប៉ុននេះឲ្យវាយល់ចឹង ឲ្យវានឹកឃើញម៉ែផង ដូចថាពួកម៉ាកបនភឿន ដូចថាទៅសេបស្ទឹជក់គ្រឿងញៀនអីខ្ញុំខំអប់រំកូនខ្ញុំខ្លាច ខ្លាចដូចថាកូនទៅរៀននៅឆ្ងាយចឹង ហើយម៉ែនៅនេះ ហើយយើងមិនបានតាមដានកូនទេរាល់ថ្ងៃ មិនដឹងជាចរិកគេរបៀបយ៉ាង ម៉េច ។

វណ្ណៈ: បាទ ។

ភី: ចឹងខ្ញុំខំយកគំនិតមួយហ្នឹងលើកឲ្យកូនវាយល់ ។

វណ្ណៈ: បាទ ។

ភី: ឲ្យវាយល់ឲ្យវានឹកឃើញ ថាម៉ែខំចិញ្ចឹមតាំងពីតូចរហូតដល់ខ្លួនពេញវ័យប៉ុននេះហើយដូចជួយ ទុក្ខកត្តិយសឲ្យម៉ែចឹង ខ្ញុំខំអប់រំចឹងដែលរាល់ថ្ងៃ ។

វណ្ណៈ: ចឹងអ៊ំបើសិនជាសៀវភៅប្រវត្តិសាស្ត្រទាំងអស់ ខាងខ្ញុំស្រាជ្រាវឬខាងណាផ្សេងសរសេរទាក់ ទងហ្នឹងប្រវត្តិសាស្ត្រហើយបានដាក់បង្រៀនទៅក្នុងសាលាឲ្យក្មេងរៀនហ្នឹង អ៊ំគិតថាសៀវភៅ ហ្នឹងអាចផ្តល់ចំណេះដឹងដល់កូនចៅជំនាន់ក្រោយដែរឬក៏យ៉ាងម៉េច?

ភី៖ អាហ្នឹងបើចង់ក្រងជាឯកសារចឹង ដល់ពេលនេះចឹង ដូចថាខ្ញុំចឹងធ្លាប់កាត់ចឹង ខ្ញុំនិយាយប្រាប់កូនវាមិនជឿទេ ដូចថាខាងរដ្ឋាភិបាលចង់ក្រងជាឯកសារចឹង យកទៅឲ្យវារៀនវាមើលទៅវាអាចយល់ហើយ យល់ហើយម៉ែហ្នឹងខំអប់រំបន្តទៅវាយល់ហើយវាមើលឃើញ ដូចថាប្រវត្តិតស៊ូពីមុនមកម្តាយយ៉ាងម៉េច វាយល់ខ្លួនវា វាដឹងហើយ ។

វណ្ណៈ៖ ចឹងអ៊ំគិតថា កូនចៅដែលបានរៀនសូត្រហ្នឹង តើមានសារសំខាន់ទៅថ្ងៃក្រោយដែលទេ?

ភី៖ ចាស!មាន ។

វណ្ណៈ៖ ចឹងបើនិយាយទាក់ទងទៅហ្នឹង បើសិនជាមានជនបរទេសណាមួយឬជនជាតិថៃ-យួន វាមករស់នៅក្បែរភូមិយើងតើអ៊ំសប្បាយចិត្តទេ?

ភី៖ និយាយរួមមកនៅដំបូងយើងមិនអាចក្តាប់អត្តចរិកគេបានមិនសប្បាយដែលហ្នឹង ព្រោះយើងមិនស្គាល់ប្រវត្តិគេ អត់សប្បាយដែលហ្នឹង ។

វណ្ណៈ៖ ចឹងបើសិនជាខ្មែរយើងមិនអីទេ?

ភី៖ បើខ្មែរយើងៗដឹងតែម្តង ម្យ៉ាងខ្មែរយើង យើងនិយាយតចឹងវាស្តាប់បានហើយ ហើយបរទេសភាសាគេផ្សេង ភាសាយើងផ្សេងស្តាប់គ្នាមិនបានវាពិបាកដែរ ។

វណ្ណៈ៖ ចឹងអ៊ំធ្លាប់ឆ្លងកាត់មករហូតមកដល់សព្វថ្ងៃហ្នឹង តើនៅក្នុងសម័យសង្គ្រាមឬនៅក្នុងសម័យណាមួយអ៊ំដែលឃើញគេចាប់មនុស្សអីឬគេធ្វើទារុណកម្មអីអ៊ំមានដែលឃើញទេ?

ភី៖ ខ្ញុំមិនដែលជួបទេ ។

វណ្ណៈ៖ ចឹងអ៊ំខ្ញុំអរគុណអ៊ំច្រើនហើយបានបានចំណាយពេលមួយម៉ោងមកនេះ ។

ភី៖ ចាស ។

វណ្ណៈ៖ ចឹងអរគុណអ៊ំច្រើន ។

ភី៖ ចាស ។

**ចប់**